ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# សវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ

Auditing of General Department of Taxation

**ជំនាញៈ សវនកម្ម**

**រៀបរៀងដោយៈ ជួន ចាន់ថន**

**អត្តលេខ:** MA20/007

**ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤**

ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# សវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ

# Auditing of General Department of Taxation

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ប្រធានបទ៖ សវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឱម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្ម នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល២ឆ្នាំសិក្សារួចមក ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យ ពន្ធ ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់ សម្រាប់តម្រូវការស្ថាប័នទាំងអស់មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន វិទ្យាស្ថានក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបាន ជាពិសេសនោះ គឺមុខវិជ្ជាសវនកម្មដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹង ដើម្បីរៀបចំ និងកាន់កាប់បញ្ជីនិងរបាយការណ៍ឱ្យបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង និងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។ ដោយខ្ញុំបាទយល់ថាចំណេះដឹងខាងសវនកម្ម ជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់ សម្រាប់សវនករទាំងអស់ធ្វើការសិក្សាស្វែងយល់ និងស្របពេលដែលខ្ញុំបាទមានឱកាសបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះ ទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«សវនកម្មពន្ធដារ របស់អគ្គនាយដ្ឋានពន្ធដារ»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីសវនកម្ម។ ខ្ញុំបាទសង្ឃឹមថា ការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀត ដែលមានបំណងលើការសិក្សាពីជំនាញសវនកម្ម។

ជាទីបញ្ចប់ខ្ញុំបាទ សូមមេត្តាខន្តីអភ័យទោសពីសំណាក់សាស្ត្រាចារ្យ រៀមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំបាទរីករាយនិងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្មនៃវិទ្យាស្ថាន វ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្ដល់នូវការលើកទឹកចិត្ត អនុគ្រោះដល់ខ្ញុំបាទរហូត ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត គង ឱម** និងសាស្ត្រាចារ្យ **យ៉ាក ឧុទ្ធី** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់ខ្ញុំបាទឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំបាទ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ខ្ញុំបាទសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ថ្ងៃ.................ខែ................ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០....

**ហត្ថលេខា**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារ បានបង្កើតឡើងក្នុង ឆ្នាំ១៩៥៣ តែត្រូវបានលុបបំបាត់វិញក្នុងរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយរបបប្រល័យពូជសាសន៍ត្រូវបានដួលរលំ នាយកដ្ឋានពន្ធដារបានបង្កើតឡើងវិញក្នុងឆ្នាំ ១៩៨០ បន្ទាប់មកនាយកដ្ឋានពន្ធដារបានដំឡើងឈ្មោះទៅជាអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីទទួលបាននូវតារាងខាងលើ ដែលបង្ហាញពីចំណូលពន្ធរយៈពេលដប់ឆ្នាំបន្តបន្ទាប់ គ្នាមកយើងសង្កេតឃើញថា ចំណូលពន្ធ គឺមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ។ ដោយជា មធ្យមមានកំណើនប្រមាណ 22.35% ក្នុងមួយឆ្នាំ ដែលក្នុងនោះឃើញថាក្នុងឆ្នាំ២០០៧សម្រេចបាន កំណើនច្រើនជាងគេ ដែលកើនដល់ទៅ 42.14% ឯឆ្នាំ២០០៩ កើនបានត្រឹមតែ 0.51% ប៉ុណ្ណោះ ដោយសារការរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨។

តាមការពិតការបង់ពន្ធ វាគឺជាការចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានលុយយក ទៅចំណាយដោយមិនចាំបាច់បោះពុម្ពលុយ ដែលអាចបង្កឲ្យមានបញ្ហាអតិផរណា។ សម្រាប់កម្ពុជា ការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់កពឹងផ្អែកលើជំនួយពីបរទេស។ សម្រាប់អ្នកបង់ពន្ធ ថ្វីដ្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញ ជាក់លាក់ក៏ពិតមែន ក៏ប៉ុន្តែគេអាចទទួលបានផលប្រយោជន៍ជាច្រើន ដោយផ្ទាល់ ឬដោយ ប្រយោល ពីការបង់ពន្ធនេះ ពីព្រោះថា លុយដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅ លើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាអ្នកទទួលបន្ទុក ផ្តល់សេវារដ្ឋបាល ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ ប្រទេស។

# មាតិកា

ទំព័រ


អារម្ភកថា ........................................................................................................ i
សេចក្តីថ្លែងអំណរគុណ ........................................................................................ ii
អំណះអំណាង ...................................................................................................... iii
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................................................ iv


## ជំពូកទី១: សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ.............................................................................. ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................................................... ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ............................................................................ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ..................................................... ២
១.៤.១ ទំហំ ដែនកំណត់ ............................................................................................ ២
១.៤.២ វិសាលភាព........................................................................................................២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ................................................................................. ៣
១.៥.១ វិធីសាស្ត្រនៃការស្រាវជ្រាវ ............................................................................... ៣
១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ ...............................................................................៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ.............................................................................. ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................................................ ៣


## ជំពូកទី២: រំលឹកទ្រឹស្តី


២.១ លក្ខណៈទូទៅនៃសវនកម្មពន្ធដារ ...........................................................................៥
២.១.១ និយមន័យពន្ធ...........................................................................................៥
២.១.២ ប្រវត្តិពន្ធ ..................................................................................................៥
២.១.៣ ប្រភេទពន្ធ ..................................................................................................៦
២.២ ប្រភេទនៃការធ្វើសវនកម្ម.................................................................................៩
២.២.១ និយមន័យសវនកម្ម.....................................................................................៩
២.២.២ ប្រវត្តិនៃសវនកម្ម...................................................................................... ៩
២.២.៣ ប្រភេទនៃសវនកម្ម....................................................................................១០
២.៣ នីតិវិធីក្នុងការធ្វើសវនកម្ម ..................................................................................១១
២.៣.១ និយមន័យនិតិ...........................................................................................១១
២.៣.២ ប្រភេទនៃនីតិវិធី.........................................................................................១១

## ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ


៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ. ........................................ ១៤
៣.១.១ ប្រវត្តិរបស់អគ្គនាយដ្ឋានពន្ធដារ ........................................ ១៤
៣.១.២ គោលនយោបាយ ........................................ ១៥
៣.១.៣ បេសកកម្ម និងទស្សនវិស័យ ........................................ ១៦
៣.១.៤ តួនាទី និងកាតព្វកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ........................................ ១៦
៣.២ ប្រភេទនៃធ្វើសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ ........................................ ១៧
៣.៣ នីតិវិធីនៃការធ្វើសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ ........................................ ១៩


## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង........................................ ២៧
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ២៨


## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ........................................ ៣០
៥.២ ការផ្តល់អនុសាសន៍ ........................................ ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានរបបដឹកនាំវិវត្តន៍ ពីសម័យកាលមួយទៅសម័យកាលមួយ ដែលមានសេដ្ឋកិច្ច នយោបាយ ច្បាប់ និងការគ្រប់គ្រងទៅតាមព្រឹត្តិការណ៍ដែលផ្លាស់ប្តូរ និងកើតមានឡើង នៅ ក្នុងសម័យកាលនីមួយៗ ក្នុងនោះទៀតសោធប្រទេសកម្ពុជាក៏បានបង្កើតឱ្យមាននូវប្រព័ន្ធពន្ធឡើង គឺក្នុងគោលបំណងប្រមូលពន្ធពីប្រជាពលរដ្ឋ ដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។ ម្យ៉ាងវិញទៀតយើងឃើញថា ប្រព័ន្ធពន្ធដារនៅកម្ពុជា ក៏មានការប្រែប្រួលទៅតាមសម័យកាលដឹកនាំផ្សេងៗគ្នាដែរ តួយ៉ាងដូចជា នៅក្នុងសម័យកាលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំង ដែលបាន យកពន្ធទៅលើ មនុស្ស សត្វពាហនៈ ដីធ្លី ស្រែ ចម្ការ ផ្ទះសម្បែងជាដើម។ល។

ដោយឡែកនៅពេលបច្ចុប្បន្ននេះប្រព័ន្ធពន្ធដារនៅកម្ពុជា ត្រូវបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ ទៅលើ គោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធព្រមទាំងបែបបទការងារ សំដៅដល់ការពង្រឹងគ្រប់គ្រងការប្រមូលពន្ធឱ្យមានប្រសិទ្ធភាព និងតម្លាភាព។ ដោយអនុវត្តន៍ទៅតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តន៍កាលពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៤ អគ្គនាយកដ្ឋានពន្ធដារ បានអនុវត្តន៍ដោយជោគជ័យ និងសម្រេចបាននូវគោលដៅនៃដំណាក់កាលទី១។ ចំណូលពន្ធដែលទទួលបានក៏មានលទ្ធផលល្អប្រសើរជាងមុន នោះបញ្ជាក់ឱ្យឃើញថាការគោរពប្រត្តិបត្តិច្បាប់ របស់អ្នកជាប់ពន្ធមានការកើនឡើងច្រើនជាងមុន។ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើការប្រមូលចំណូលពន្ធសម្រាប់ធ្វើការអភិវឌ្ឍនូវគ្រប់វិស័យដូចជា បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ កងទ័ព សាងសង់ស្ពាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ចំណាយទូទៅសង្គមកិច្ច សេដ្ឋកិច្ច និងអភិវឌ្ឍ ការពារព្រំដែនជាដើម។ ក្នុងនោះដែរ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវកម្មវិធីសារពើពន្ធជាច្រើន ដើម្បីលើកទឹកចិត្តផ្នែកពន្ធដារ និងធ្វើការប្រមូលចំណូលពន្ធទៅតាមប្រភេទពន្ធ អាករនីមួយៗផ្សេងៗគ្នាដែលមានដូចជា៖ ពន្ធលើប្រាក់ចំណូល ពន្ធប៉ាតង់ ពន្ធលើប្រាក់បៀវត្សនិងអត្ថប្រយោជន៍បន្ថែម ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធតែមប្រ៍សារពើពន្ធ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធកាត់ទុកពន្ធលើឈ្នួលផ្ទះនិងដី អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ អាករលើតម្លៃបន្ថែម។ល។

ដោយយោងតាមប្រភពចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី «សវនកម្មពន្ធដារ របស់អគ្គនាយដ្ឋានពន្ធដារ» យកមកស្រាវជ្រាវ និង រៀបចំជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ពន្ធដារ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកបង្កើនថវិកាជាតិសម្រាប់ធានានូវសេចក្តីត្រូវការ និងចំណាយសាធារណៈដែលកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ការប្រមូលពន្ធមិនមែនអាចប្រមូល

បានដោយគ្រាន់តែមានច្បាប់ពន្ធដារតែប៉ុណ្ណោះទេ គឺអ្នកជាប់ពន្ធក៏ត្រូវចូលរួមយល់ដឹងពីសារៈសំខាន់នៃពន្ធដារ ព្រមទាំងច្បាប់ពន្ធដារហើយរាយការណ៍និងបង់ពន្ធជូនរដ្ឋដោយស្មោះត្រង់នោះទើបរដ្ឋអាចទទួចំណូលបានយ៉ាងពេញលេញ។ ដូច្នេះហើយទើបមានសំណួរខ្លះបានចោទសួរថា៖

១.តើការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារមានប៉ុន្មានប្រភេទ?

២.តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីដូចម្ដេចក្នុងការធ្វើសវនកម្ម?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ គឺដើម្បីសិក្សាស្វែងយល់បន្ថែមទៅលើ៖

- ការបកស្រាយខ្លះៗទៅលើប្រភេទពន្ធផ្សេងៗ
- ប្រភេទនៃសវនកម្មពន្ធដារ
- សវនកម្មលើលិខិតស្នាម(Desk Audit)
- សវនកម្មមានកម្រិត(Limited Audit)
- សវនកម្មពេញលេញ(Comprehensive Audit)។
- ស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយក្នុងការដកហូតពន្ធរបស់ពន្ធដារ។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ;

### ១.៤.១ ទំហំ ដែនកំណត់

តាមការស្រាវជ្រាវនៃប្រធានបទខាងលើគឺ ប្រសិនបើយើងលើកយកចំណុចដែលទាក់ទងទៅនឹងទំហំ និងដែនកំណត់នៃពន្ធនោះគឺមានន័យទូលំទូលាយណាស់ ហើយក៏មានច្រើនប្រភេទច្រើនសណ្ឋានផងដែរ ដូច្នេះ ហើយតម្រូវឱ្យជ្រើសរើសយកពន្ធមួយ មកធ្វើការសិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ នៅត្រង់ ចំណុចនេះដែរយើងនឹងលើកយកប្រធានបទ សវនកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារមកនិយាយវែកញែក ឱ្យកាន់តែច្បាស់លាស់ថែមមួយកម្រិតទៀត ដើម្បីយល់ដឹងនូវវិធាននិងនិតិវិធី ព្រមទាំងសិទ្ធនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធនិងអ្នកជាប់ពន្ធពាក់ពន្ធនិងការធ្វើសវនកម្មពន្ធដារ និងបណ្ដាអាជីវករ ឬម្ចាស់ក្រុមហ៊ុនទាំងអស់បានដឹងថា តើនិតិវិធីនៃការធ្វើសវនកម្មពន្ធដារមានអ្វីខ្លះ? ដោយ ខ្ញុំផ្ដោតសំខាន់ទៅលើអគ្គនាយកដ្ឋានពន្ធដារ ដែលមានទីតាំងនៅរាជធានីភ្នំពេញ អាគារកែងមហាវិថី សហព័ន្ធរុស្សី(១០០)និងម៉ៅសេទុង(២៤៥)និងលើកយកដំណើរការនៃនិតិវិធីសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ មកសិក្សាបកស្រាយ។

### ១.៤.២ វិសាលភាព

ក្នុងការសិក្សាស្រាវជ្រាវនេះផងដែរតម្រូវឱ្យមានការកំណត់វិសាលភាពឱ្យបានច្បាស់លាស់ ដូច្នេះខ្ញុំបាទមិនបានបកស្រាយនូវពត៌មានទាំងអស់ឱ្យបានក្បោះក្បាយនោះទេ ដោយខ្ញុំបាទផ្ដោតសំខាន់ទៅលើនីតិវិធីសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ នៅក្នុងឆ្នាំ២០២៣។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវរួមមាន

- ការពិភាក្សា និងប្តូរយោបល់គ្នាទៅវិញទៅមក
- ដកស្រង់ចេញគេហទំព័រ (Website) នៅលើប្រព័ន្ធអ៊ីនធើណែត និងបានមកពីបណ្ណាល័យរបស់វិទ្យាស្ថាន វ៉ាន់ដា រួមបញ្ចូលជាមួយចំណេះដឹងដែលធ្លាប់បានសិក្សា
- ការសាកសួរលោកគ្រូ អ្នកគ្រូដែលបង្រៀននៅក្នុងថ្នាក់

### ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ

នៅក្នុងការស្រាវជ្រាវសំខាន់បំផុតគឺការប្រមូលទិន្នន័យ ដើម្បីឱ្យរបាយការណ៍របស់យើងកាន់តែមានប្រសិទ្ធភាពថែមទៀត ទិន្នន័យទាំងនោះរួមមាន៖

- ទិន្នន័យទី១ : ការប្រមូលទិន្នន័យនៃការស្រាវជ្រាវដំបូងគឺការសាកសួរ និងស្រាវជ្រាវនៅសាលាជាតិនៃអគ្គនាយកដ្ឋានពន្ធដារ។
- ទិន្នន័យទី២ : សម្រាប់ការប្រមូលទិន្នន័យនេះគឺបានមកពីបណ្ណាល័យសាលាជាតិពន្ធដារ និងការស្វែងរកយកពីប្រព័ន្ធអ៊ីនធើណេត (www.tax.gov.kh)

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន៖

- ទទួលបទពិសោធន៍ដែលបង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកការងារធ្វើ
- ធ្វើឱ្យអ្នកស្រាវជ្រាវយល់ដឹងអំពីការងាររបស់អគ្គនាយកដ្ឋានពន្ធដារ
- ធ្វើឱ្យយើងដឹងពីការរៀបចំរចនាសម្ព័ន្ធ ក៏ដូចជាភារកិច្ចរបស់បុគ្គលិកនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ
- អាចរក្សាទុកជាឯកសារដល់និស្សិតជំនាន់ក្រោយបានយល់ដឹង
- អាចបង្កើតនូវចំណេះដឹងឱ្យកាន់តែទូលំទូលាយ និងទទួលបានពិសោធន៍ថ្មី...។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបែងចែកជា៥ជំពូកមានដូចខាងក្រោម៖

- ជំពូកទី១ សេចក្តីផ្តើម៖ ជំពូកនេះបានបង្ហាញពី លំនាំដើមបញ្ហា ចំណោទបញ្ហា គោលបំណងនៃ ការស្រាវជ្រាវ ទំហំនិងដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ
- ជំពូកទី២ សវនកម្មពន្ធដារ៖ ជំពូកនេះលើកឡើងអំពី និយមន័យពន្ធ បទប្បញ្ញត្តិនៃសវនកម្មពន្ធដារ
- ជំពូកទី៣ ដំណើរការនៃសវនកម្មពន្ធដារ ៖ ជំពូកនេះបានលើកឡើងពី ប្រវត្តិកកើត នៃអគ្គនាយកដ្ឋានពន្ធដារ ច្បាប់ពន្ធនៃការសវនកម្មពន្ធដារ យុទ្ធសាស្ត្រការសវនកម្មពន្ធដារ
- ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖ ជំពូកនេះធ្វើការវិភាគទៅលើផលវិជ្ជមាន និងអវិជ្ជមាននៃផលប្រយោជន៍ក្នុងការធ្វើវិធាននិងនិតិវិធី ព្រមទាំងសិទ្ធនិងកាតព្វកិច្ចរបស់រដ្ឋបាលសាពើពន្ធនិងអ្នកជាប់ពន្ធពាក់ពន្ធនិងការធ្វើសវនកម្មពន្ធដារ

- ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖ ជំពូកនេះបានធ្វើការសន្និដ្ឋានដោយសង្ខេបទៅលើគ្រប់ចំណុចដែលបានវិភាគ និងការផ្តល់យោបល់ជាអនុសាសន៍ទៅគ្រប់ចំណុចដែរត្រូវកែលម្អ។

# ជំពូកទី២

# សវនកម្មពន្ធដារ

## ២.១ លក្ខណៈទូទៅនៃសវនកម្មពន្ធដារ

### ២.១.១ និយមន័យពន្ធ

ពន្ធ សំដៅដល់អាករ (ពន្ធផ្ទាល់និងពន្ធប្រយោល)។ ពន្ធ គឺជាវិភាគទានលក្ខណៈកាតព្វកិច្ច(ចាប់បង្ខំ)ស្របតាមច្បាប់កំណត់ ដែលអ្នកជាប់ពន្ធ ទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ការយកពន្ធ ជាមធ្យោបាយជាក់ស្តែងមួយដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនប្រាក់ចំណូល និងបំពេញការចំណាយរបស់រដ្ឋ។

ពន្ធ គឺជាបន្ទុករបស់រដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធ ហើយទទួលតម្លៃតបស្នងពីរាជរដ្ឋាភិបាលតាមរយៈទំនិញ ឬសេវាសាធារណៈ។ [1]

ពន្ធ គឺជាឧបករណ៍របស់រាជរដ្ឋាភិបាលដែលបង្កើតឡើងដើម្បីកៀរគរចំណូលចូលថវិកាជាតិសម្រាប់ចំណាយសាធារណៈ។

ពន្ធ គឺជាកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប ក្នុងការបង់ជាប្រាក់ ឬទំនិញទៅឱ្យរដ្ឋដោយស្ម័គ្រចិត្ត។ដើម្បីថែរក្សានូវផលប្រយោជសាធារណៈទាំងនោះចាំបាច់ត្រូវទាមទារឱ្យមានការចូលរួមពីសំណាក់មហាជន។

ពន្ធ ជាការបង្ខិតបង្ខំ ឬជាការចាំបាច់ដោយខានពុំបាន ដែលរដ្ឋត្រូវតែដក ឬប្រមូល ផ្អែកលើមូលដ្ឋានដែលកំណត់ដោយច្បាប់ និងមានទិសដៅបំពេញរាល់ការប្រើប្រាស់របស់រដ្ឋ។ តាមការស្រាវជ្រាវ ការកកើតពន្ធឬទ្រឹស្តីទាក់ទងនិងពន្ធ គេរកឃើញថាបានកើតឡើងស្របជាមួយនឹងការកកើត នៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែលមានការកើតចេញឡើងនូវទម្រង់អង្គការចាត់តាំងនៃមនុស្ស។

ពន្ធ ជារូបភាពមួយនៃការបែងចែកឡើងវិញនូវចំណូលជាតិ ដែលរដ្ឋបានប្រើប្រាស់ដើម្បីចលនាមួយផ្នែកចំណូលរបស់បណ្តាអង្គការចាត់តាំងសេដ្ឋកិច្ច (ក្រុមហ៊ុនសហគ្រាស...) និងរបស់ពលរដ្ឋដើម្បីបម្រើតម្រូវការរួមដល់អង្គភាពទាំងមូល។ [2]

ពន្ធ មានលក្ខណៈបង្ខំហើយមិនសងវិញដោយផ្ទាល់ ប៉ុន្តែបានសងវិញ ដោយប្រយោលតាមមាគ៌ាផ្សេងៗគ្នា។

ពន្ធ ជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាព ដែលកំណត់ដោយច្បាប់។

### ២.១.២ ប្រវត្តិពន្ធ

ពន្ធ ដំបូងត្រូវបានកំណត់ចំពោះប្រទេសអេហ្ស៊ីប។ នៅសម័យដើមនៃសាធារណរដ្ឋរ៉ូម៉ាំង ពន្ធសាធារណៈមានការវាយតម្លៃតិចតួចលើទ្រព្យសម្បត្តិ និងទ្រព្យដែលជាកម្មសិទ្ធិ។ អត្រាពន្ធ ធម្មតាគឺ ១% ហើយពេលខ្លះអាចឡើងដល់ ៣% ក្នុងស្ថានភាពដូចជាសង្គ្រាម។ ពន្ធតិចតួចទាំងនេះត្រូវបានគេយកទៅលើដីធ្លី ផ្ទះ និងអចលនទ្រព្យផ្សេងទៀត មានដូចជាទាសករ សត្វរបស់របរផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិរូបិយវត្ថុ។ មនុស្សម្នាក់មានទ្រព្យកាន់តែច្រើនពន្ធកាន់តែច្រើន។ ពន្ធត្រូវបានប្រមូលពីបុគ្គលម្នាក់ៗ។[3]

---

[1] ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, មាត្រា១២៨

[2] http://cambotax.com/taxes-law/cambodia-taxes-law/ (10-11-2023)

[3] History of Taxes | TaxEDU | Tax Foundation (01-10-2023)

ចំពោះប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។ ព្រះអង្គម្ចាស់នរោត្តមសីហនុត្រូវបានឡើងសោយរាជ្យបន្ត ដែលការតែងតាំងដំបូងបង្អស់លើព្រះអង្គក្នុងឆ្នាំ១៩៤១។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតនៅឆ្នាំ ១៩៥៣ បន្ទាប់មកត្រូវលុបបំបាត់ចោលនៅឆ្នាំ១៩៧៥-១៩៧៩ ដោយសារ សង្គ្រាម(របបប៉ុលពត)។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងដំណាក់កាលដំបូងឆ្នាំ ១៩៨០ ដោយបានអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារ បានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីអនុវត្ត និងមានការចែងច្បាប់ព្រមទាំងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតនូវរបបកំណត់ពន្ធជា៣ប្រភេទ៖ របបពិត របបម៉ៅការ និង របបបំពេញដែលមានចែងដាច់ដោយឡែក។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាយើងមានតែរបបពិត (ស្វ័យប្រកាស)តែមួយប៉ុណ្ណោះ។

### ២.១.៣ ប្រភេទពន្ធ

ពន្ធលើអចលនទ្រព្យ៖ គឺជាពន្ធដែលប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី ១០០លានរៀល និងមានទីតាំងស្ថិតនៅក្នុងភូមិសាស្រ្តរដ្ឋបាលរាជធានី និងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ ពន្ធនេះជាប្រភេទពន្ធផ្ទាល់ដែលតម្រូវឱ្យអ្នកជាប់ពន្ធដែលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួល ផលប្រយោជន៍ចុងក្រោយមកចុះបញ្ជីអចលនទ្រព្យ និងធ្វើការប្រកាសបង់ប្រាក់ពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញាជារៀងរាល់ឆ្នាំ។ ការប្រមូលពន្ធលើអចលនទ្រព្យនេះគឺសម្រាប់ជាផលប្រយោជន៍ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

អាករសម្រាប់បំភ្លឺសាធារណៈ៖ ត្រូវបានកំណត់តាមអត្រា៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាមេរ័យ និងបារី។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ៖ ពន្ធនេះត្រូវអនុវត្តទៅលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ។ អត្រាពន្ធ និងរយៈពេលត្រូវបង់ ត្រូវកំណត់តាមការប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាករស្នាក់នៅ៖ អាករលើការស្នាក់ត្រូវបានកំណត់តាមអត្រា ២% លើការស្នាក់នៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់សេវាស្នាក់នៅត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។[4]

ពន្ធលើដីធ្លីមិនបានប្រើប្រាស់៖ ពន្ធនេះកំណត់លើដីដែលគ្មានសំណង់និងដីដែលមានសំណង់បោះបង់ ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ ពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធិករតាមគំរូលិខិតប្រកាសផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ

[4] អគ្គនាយកដ្ឋានពន្ធដារ | ទំព័រដើម (tax.gov.kh) (10-10-10-2023)

ពន្ធនេះត្រូវកំណត់តាមអត្រា ២% លើមូលដ្ឋានកំណត់ពន្ធដែលបានចែងក្នុងមាត្រា ៣០ យ៉ាងយឺតបំផុត នៅថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រមូលពន្ធ។

ពន្ធប្រថាប់ត្រា៖ ត្រូវបានបង់ដោយអ្នកទទួលកម្មសិទ្ធិ ទទួលសិទ្ធិកាន់កាប់ដីធ្លីដែលគ្មានសំណងគិតជាសមាមាត្រ លើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្លៃផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់។ ប៉ុន្តែដើម្បីឱ្យមានភាពងាយស្រួល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការគិតគូរប្រាក់ពន្ធដែលត្រូវបង់។

ពន្ធប៉ាតង់៖ ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ អ្នកជាប់ពន្ធដែលទើបចាប់ផ្តើមប្រកបអាជីវកម្មត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ឬបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្ម ក្នុងរយៈពេល ៦ខែចុងឆ្នាំ។ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅ ក្នុងខេត្ត-ក្រុងតែមួយមិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ ប៉ុន្តែបើមានមុខរបរអាជីវកម្មខុសៗគ្នា ឬស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមមុខរបរនីមួយៗ និងទៅតាមខេត្ត-ក្រុងដោយឡែកៗពីគ្នា។ អ្នកជាប់ពន្ធត្រូវដាក់តាំងឬ ព្យួរប័ណ្ណប៉ាតង់នៅទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួន។

លើឈ្នួលផ្ទះ និង ដី៖ ពន្ធលើឈ្នួលផ្ទះ និង ដីត្រូវកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល៖

- អគារដែលសង់លើដីដូចជាៈ ផ្ទះ រោងចក្រ ភណ្ឌាគារ ការិយាល័យ ។ល។
- ហត្ថបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម
- ឋាបនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហកម្មដែលនៅនឹងមួយកន្លែង អគារធំៗដែលទុកដាក់ជាតុរាវ ឬផលិត
- ផលផ្សេងៗ ដូចជា ប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ
- ផ្ទះអណ្តែតទឹក កប៉ាល់សម្រាប់ធ្វើជាលំនៅដ្ឋាន ឬ ដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លីដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ជម្រុងថ្ម បឹងបួរ ស្រែអំបិល
- ពន្ធនេះត្រូវប្រមូលពីកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករ
- អត្រាពន្ធលើឈ្នួលផ្ទះ និងដីត្រូវបានកំណត់ស្មើនឹង ១០%នៃប្រាក់ឈ្នួលជុល។ ប្រាក់ឈ្នួលជួល គឺជាប្រាក់ឈ្នួលដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងជាមួយអ្នកជួល។

អាករពិសេសលើទំនិញ និងសេវាមួយ៖ ត្រូវបានកំណត់លើទំនិញនិងសេវាមួយចំនួន។ ទំនិញដែលជាប់អាករនេះមានភេសជ្ជៈ ស្រា ស្រាបៀរ (២០%) និង បារី (១៥%)។ សេវាមួយចំនួនមានសេវាលំហែកំសាន្ត (១០%) ការដឹកជញ្ជូនអ្នក ដំណើរតាមផ្លូវអាកាស (១០%) និងសេវាទូរស័ព្ទ (៣%)។[5] អ្នកជាប់ពន្ធដែលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនេះត្រូវ ទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

[5] ដូចលេខ4

អាករលើតម្លៃបន្ថែម៖ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមាន កាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ ឬសេវាឱ្យអតិថិជន។ ទំនិញសំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លីនិងប្រាក់កាស រីឯសេវា សំដៅដល់ការផ្តល់អ្វីមួយ ដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវាត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

ពន្ធលើប្រាក់ចំណូល៖ ត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជានឹងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ចំណូលកំណត់លើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

ពន្ធកាត់ទុក៖ អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ លើការទូទាត់មុនការកាត់ទុកប្រាក់ពន្ធ។

ពន្ធអប្បបរមា៖ ជាពន្ធមួយដាច់ដោយឡែកនិងផ្សេងៗពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមអត្រា ១ ភាគរយលើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ៖ សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិតរួមទាំង គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១% នៃផលរបរគិតរួមបញ្ចូលពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្ស ដែលរូបវន្តបុគ្គលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។ រូបវន្តអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស នៅមុនពេលបើកប្រាក់បៀវត្សឱ្យដល់ និយោជិត និងបង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី២០នៃខែបន្ទាប់ពីខែ ដែលប្រាក់បៀវត្សត្រូវបានបើក។[6]

[6] ដូចលេខ4

## ២.២ ប្រភេទនៃការធ្វើសវនកម្ម

### ២.២.១ និយមន័យសវនកម្ម




សវនកម្មពន្ធដារ សំដៅដល់ការពិនិត្យបញ្ជាក់លើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធ បានត្រឹមត្រូវ តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មពន្ធដារគឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រង និងប្រមូលពន្ធឲ្យមាន តម្លាភាព និងប្រសិទ្ធភាព ដើម្បីជានាសមធម៌ក្នុងការបង់ពន្ធ។[7]

### ២.២.២ ប្រវត្តិនៃសវនកម្ម

សវនកម្មមានអាយុកាលដូចគណនេយ្យដែរហើយមានសញ្ញានៃអត្ថិភាពរបស់វានៅក្នុងវប្បធម៌បុរាណទាំងអស់ដូចជា មេសូប៉ូតាមៀ ក្រិក អេហ្ស៊ីប រ៉ូម ចក្រភពអង់គ្លេស និងឥណ្ឌា។Arthashastra បានលម្អិតអំពីច្បាប់ Kautilya សម្រាប់គណនេយ្យ និងសវនកម្មហិរញ្ញវត្ថុសាធារណៈ។នៅសម័យបុរាណ គោលបំណងសំខាន់នៃសវនកម្មគឺដើម្បីទទួលបានព័ត៌មានអំពីប្រព័ន្ធហិរញ្ញវត្ថុ និងកំណត់ត្រានៃអាជីវកម្ម។ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះ សវនកម្មបានចាប់ផ្តើមរួមបញ្ចូលមុខវិជ្ជាដែលមិនមែនជាហិរញ្ញវត្ថុ ដូចជាសុវត្ថិភាព សុវត្ថិភាពដំណើរការប្រព័ន្ធព័ត៌មាន និងបញ្ហាបរិស្ថាន។ជាមួយនឹងអង្គការមិនរកប្រាក់ចំណេញ និងភ្នាក់ងាររដ្ឋាភិបាល មានតម្រូវការកើនឡើងសម្រាប់ការអនុវត្តសវនកម្ម ដោយពិនិត្យមើលភាពជោគជ័យរបស់ពួកគេក្នុងការបំពេញគោលបំណងបេសកកម្មនៃអាជីវកម្ម។[8]

[7] សវនកម្មពន្ធដារ (advancegroupkh.com) (11-10-2023)
[8] https://www.rcvacademy.com/auditing-origin-evolution (13-10-2023)

### ២.២.៣ ប្រភេទនៃសវនកម្ម

**សវនកម្មលើលិខិតស្នាម** ត្រូវបានធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ។ ការធ្វើសវនកម្មលើលិខិតស្នាម គឺជាការ ពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធ ដែលមានភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នារវាងលិខិតប្រកាសសារពើពន្ធ ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងការប្រកាសបង់ពន្ធ របស់អ្នកជាប់ពន្ធ ។ ជាទូទៅសវកម្មនេះ ត្រូវផ្តោតសំខាន់ទៅលើ ចំណុចមិនប្រក្រតីច្បាស់លាស់នឹងងាយស្រួលដោះស្រាយដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ ដូចជាការផ្ទៀងផ្ទាត់លិខិតប្រកាសពន្ធជាមួយនឹងព័ត៌មាន ដែលរដ្ឋបាលសារពើពន្ធទទួលបានពីប្រភពផ្សេងៗជាដើម។ ក្នុងនោះ រដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធមកបំភ្លឺនិងបង្ហាញឯកសារទាក់ទិននឹងភាពមិនប្រក្រតីដែលបានរកឃើញលើ លិខិតប្រកាសសារពើពន្ធ។ ក្នុងករណីដែលហានិភ័យទាំងឡាយដែលរកឃើញមានលក្ខណៈស្មុគស្មាញជាប្រព័ន្ធ ឬអាន ហានិភ័យខ្ពស់ ការធ្វើសវនកម្មលើលិខិតស្នាមត្រូវបញ្ឈប់និងផ្ទេរនៅជាការធ្វើសវនកម្មដល់ទីកន្លែងវិញ។ សវកម្មប្រភេទ នេះត្រូវធ្វើក្នុងអំឡុងពេល ១២ ខែ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

**សវនកម្មដល់ទីកន្លែង** គឺជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាសដែលជាកម្មវត្ថុនៃការ ធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្តែង បញ្ជីគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។ សវនកម្ម នេះរួមមាន៖

**សវនកម្មមានកម្រិត** គឺជាការធ្វើសវនកម្មរយៈពេលខ្លីនិងឆ្លាមៗទៅលើប្រភេទពន្ធអាករមួយចំនួន ជាអាទិ៍មាន អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែមរួមទាំងការបង្វិលសង និង ពន្ធអាករផ្សេងទៀតវៀរលែងតែពន្ធលើប្រាក់ចំណូល ដោយពិនិត្យទៅលើចំណុចដែលជាហានិភ័យទាំងឡាយក្នុងបញ្ជី គណនេយ្យ និងឯកសារពាក់ព័ន្ធ។ សវនកម្មនេះអាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត (N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត (N-1)។

**សវនកម្មពេញលេញ** គឺជាការធ្វើសវនកម្មលើពន្ធអាករគ្រប់ប្រភេទ និងវាយតម្លៃលើការកាន់កាប់បញ្ជីគណនេយ្យ របស់សហគ្រាស អោយត្រូវធ្វើការត្រួតពិនិត្យជាក់ស្តែងលើប្រតិបត្តិការអាជីវកម្ម ផ្ទៀងផ្ទាត់ទៅនឹងបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្ម ដើម្បីធានាបានថាគ្រាសបានរៀបចំរបាយការណ៍ គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវតាមច្បាប់ជាធរមាន និងបានបំពេញភាពពកិច្ចបង់ពន្ធត្រឹមត្រូវតាម ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មនេះអាចធ្វើឡើងក្នុងរង្វង់ ៣ឆ្នាំជាប់ពន្ធថយក្រោយ (N-3) ប៉ុណ្ណោះ។ ក្នុងករណី មានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ឬមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេល ជាប់ពន្ធមុន ដែលតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញលើសពី៣ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាច ធ្វើឡើងក្នុងរង្វង់៥ឆ្នាំជាប់ពន្ធថយក្រោយ។ [9]ក្នុងករណីចាំបាច់នឹងមានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ដែលតម្រូវឲ្យ មានការធ្វើសវនកម្មពេញលើសពី៥ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាចអ្វីឡើងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសាពើពន្ធដោយត្រូវស្នើសុំការអនុញ្ញាតធ្វើសវនកម្ម ជាមុនពីរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើករណីជាក់ស្តែងនីមួយៗ។

[9] tax-auditing_legal-pointer_17th_kh.pdf (gmac-production.s3-ap-southeast-1.amazonaws.com)

- វៀរលែងតែក្នុងករណីមានភស្តុតាងច្បាស់លាស់ មូលដ្ឋានគិតពន្ធតែមួយ ប្រភេទពន្ធតែមួយ ដែលបានធ្វើការ កំណត់ពន្ធរួចហើយមិនត្រូវជាកម្មវត្ថុនៃការធ្វើសវនកម្មជាថ្មីម្តងទៀតទេ។

- វៀរលែងតែក្នុងករណីដូចខាងក្រោម ការធ្វើសវនកម្មដូចមានចែងក្នុងប្រការនេះ មិនតម្រូវឲ្យធ្វើលើគ្រប់ឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធទេ គឺត្រូវធ្វើឡើងតែចំពោះឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធណាដែលមានហានិភ័យដល់ចំណូលពន្ធតែប៉ុណ្ណោះ៖

១. មានការស្នើសុំពីអ្នកជាប់ពន្ធ។

២. សហគ្រាសដែលមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធមុន។

៣. មានភស្តុតាងថាសហគ្រាសបានគេចវេះពន្ធ។

ក្នុងករណីដែលរកឃើញជាយថាហេតុនូវភស្តុតាង ឬបទល្មើសជាក់ស្តែងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធ ដែលកើតមានឡើងដោយចេតនារៀបចំរបស់សហគ្រាស អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារអាចចាត់ឱ្យអង្គភាពណាមួយ ធ្វើសវនកម្មពិសេស ឬធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទៅលើសហគ្រាស។ ក្នុងការលើនេះ អង្គភាពដែលកំពុងធ្វើសវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត ឬសវនកម្មពេញលេញ ត្រូវបញ្ឈប់នឹងដកចេញ ពីកម្មវិធីសវនកម្មកម្មរបស់ខ្លួន ហើយប្រសិនបើការស៊ើបអង្កេតបទល្មើសពន្ធដារមិនឈានដល់ការប្តឹងចោទទៅតុលាការ អង្គភាពដែលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបង្វែរករណីនេះទៅអង្គភាពពាក់ព័ន្ធដើម្បីបន្តនីតិវិធីសវនកម្មវិញ។[10]

## ២.៣ នីតិវិធីក្នុងការធ្វើសវនកម្ម

### ២.៣.១ និយមន័យនីតិ

«នីតិ» មានន័យថា ឧបាយជាគ្រឿងណែនាំ បែបផែន ជាទំនឹមទំនៀម ប្រពៃណី។ ឧទាហរណ៍៖ នីតិកម្ម(ការធ្វើច្បាប់ សិទ្ធិតែងច្បាប់ អង្គច្បាប់សម្រាប់រដ្ឋនីមួយៗ) នីតិកាល(រយៈពេលដែលសភាអ្នកតែងតាំងច្បាប់)នីតិបុគ្គល(អ្នករៀបរៀងច្បាប់)នីតិប្បញ្ញត្តិ(ការបង្គាប់ឲ្យធ្វើតាមច្បាប់ដែលតែងមក)នីតិក្រម(ទម្រង់របស់ច្បាប់គឺសម្រាប់ចៅក្រមត្រូវអង្កេតពិនិត្យ សាកសួរពីបទល្មើសផ្សេងៗ) ជាដើម។[11]

### ២.៣.២ ប្រភេទនៃនីតិវិធី

**១. ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម**

ការជ្រើសរើសសហគ្រាសធ្វើសវនកម្មត្រូវធ្វើឡើងដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ការវិភាគហានិភ័យ
- បទផលបានមកពីការផ្ទៀងផ្ទាត់ផ្លូវផ្លងព័ត៌មាន (Crosscheck)

[10] ដូចលេខ 9

[11] និតិ - Search (bing.com)(01-12-2023)

- ព័ត៌មានទទួលបានពីតតិយជន
- ព័ត៌មានអំពីប្រភេទពន្ធឬវិស័យជាក់លាក់ណាមួយ
- ព័ត៌មានរបស់ក្រុមអ្នកជាប់ពន្ធណាមួយ
- ទីតាំងរបស់សហគ្រាស។ល។[12]

**២. ទោសទណ្ឌសារពើពន្ធ**

+ អំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិពន្ធដារ

- អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមានៈ
- មិនបានរក្សាបញ្ជីការគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ
- មិនអនុញ្ញាតអោយរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ
- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី
- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ

លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រាឯកសាររបាយការណ៍ឬព័ត៌មានផ្សេងៗទៀត

- ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ
- មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានការប្រាក់ ពន្ធត្រូវបង់ក្នុងរយះពេល៣០ថ្ងៃ ក្រោយ កាលបរិច្ឆេទដែលច្បាប់បានកំណត់
- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ។[13]

**៣. អំពើគេចវេសពន្ធ**

អំពើគេចវេសពន្ធរួមមានៈ

- ល្មើសដោយចេតនា ដឹងជាមុន គិតទុកជាមុន ក្នុងគោលបំណងដើម្បីបន្ថយ ឬបំបាត់ប្រាក់ពន្ធ ដែល បទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវអោយបង់
- ធ្វេសប្រហែសធ្ងន់ធ្ងរពីរលើក ដាច់ដោយឡែកពីគ្នារយៈពេល៣ឆ្នាំនៃឆ្នាំប្រតិទិន
- ធ្វេសប្រហែសធ្ងន់ធ្ងរបីលើក ឬ ច្រើនលើក ដាច់ដោយឡែកពីគ្នារយៈពេលណាមួយ

**៤. ពន្ធបន្ថែម និង ការប្រាក់**

+ពន្ធបន្ថែម ១០% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ

- ការធ្វេសប្រហែសដោយប្រកាស និង បង់ប្រាក់ពន្ធខ្វះតិចជាង១០%
- បង់ពន្ធយឺត

+ពន្ធបន្ថែម ២៥% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ

[12] ដូចលេខ7

[13] ដូចលេខ7

- ការធ្វេសប្រហែសធ្ងន់ធ្ងរដោយប្រកាស និង បង់ប្រាក់ពន្ធខ្វះច្រើនជាង១០%

+ ពន្ធបន្ថែម ៤០% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ

ក្នុងករណីដែលអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុក មានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែ មិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកាគណនេយ្យឬឯកសារផ្សេងៗ ទៀតតាមការតម្រូវ ឬមិនបានផ្តល់ពត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបាន។[14]

[14] ដូចលេខ7

# ជំពូកទី៣
# ការធ្វើសវនកម្មពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង នៅឆ្នាំ១៩៥៣ក្នុងអំឡុងពេលដែលប្រទេសជាតិមានការរីកចម្រើនស្ទើរគ្រប់វិស័យ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបប៉ុលពតបានចូលមកកម្ពុជា ដោយបានបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិ សាសនា ប្រពៃណីនិងទំនៀមទម្លាប់ គ្រប់យ៉ាងចោលទាំងអស់ រួមទាំងនាយកដ្ឋានពន្ធដារផងដែរ។ បន្ទាប់ពីបញ្ចប់សង្គ្រាមនៅឆ្នាំ១៩៨០ ពន្ធដារបានបង្កើតឡើងវិញ ដើម្បីលើកស្ទួយប្រទេសជាតិឱ្យមានការរីកចម្រើនជាងមុនរហូតដល់ឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ ។ មកដល់ពេលនេះអគ្គនាយកដ្ឋានពន្ធដារមានសាខាពន្ធដារគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា ក្នុងនោះមាន **សាខាពន្ធដារ** ជាច្រើនក៏ត្រូវបានបង្កើតឡើង ដោយមានទីតាំងស្ថិត នៅ រាជធានីភ្នំពេញនិងខេត្ត។ ដើម្បីជួយសម្រួលបន្ទុករបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រមូលពន្ធក៏ដូចជាជួយសម្រួលដល់អ្នកជាប់ពន្ធ មានភាពងាយស្រួលក្នុងការបង់ពន្ធ។ នៅព្រះរាជាណាចក្រកម្ពុជាបានបង្កើតនាយកដ្ឋានពន្ធដារតាមសេចក្តីសម្រេចលេខ ៤១៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាន៍ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៨១ ដែលមានឈ្មោះដើមហៅថា នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជ ស្ថិតនៅក្រោមនៅក្រោមការគ្រប់គ្រងរបស់មន្ទីហិរញ្ញវត្ថុ និងធនាគារខេត្តក្រុង។ ស្ថាប័ននេះបានប្តូរឈ្មោះទៅជានាយកដ្ឋានពន្ធដារដោយផ្អែកតាមអនុក្រឹតលេខ២៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងសារាចរណែនាំអនុវត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០៥៧ សហវ ចុះទី១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ។ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៨ ដោយអនុក្រឹត្យលេខ ១៣៤ អនក្រ បានតម្លើងនាយកដ្ឋានពន្ធ

ដាររបស់ទៅជា អគ្គនាយកដ្ឋានពន្ធដារ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសាខានៅតាមខេត្ត-ខណ្ឌផងដែរ។ សាខាពន្ធដារខណ្ឌដូនពេញ មានការិយាល័យចំណុះ៤ ហើយតួនាទី និងភារកិច្ចរបស់សាខាពន្ធដារជាទូទៅដូចគ្នានឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រង់អ្នកជាប់ពន្ធធំដែរ និងមានតួនាទីនិងភារកិច្ចបន្ថែមក្នុងការគ្រប់គ្រង និងប្រមូលពន្ធលើអ្នកជាប់ពន្ធតូច និងប្រភេទពន្ធមួយចំនួន ទៀត។ តួនាទី និងភារកិច្ចបន្ថែមមានជាអាទិ៍រ ៖

១. ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជីមានតួនាទីនិងភារកិច្ចបន្ថែមគឺប្រមូលតែមប្រិយ ពន្ធមធ្យោបាយលើយានយន្តគ្រប់ប្រភេទ ពន្ធឈ្នួលផ្ទះ ដី។
២. ការិយាល័យចាត់ចែងលិខិតប្រកាសមានតួនាទីនិងភារកិច្ចបន្ថែមគឺ ធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធតូចៗ
៣. ការិយាល័យសវនកម្មពន្ធមានតួនាទីនិងភារកិច្ចបន្ថែមគឺ អាចធ្វើសវនកម្មលើអ្នកជាប់ពន្ធតូចក្នុងករណីចាំបាច់។
៤. ការិយាល័យបំណុលពន្ធ មានតួនាទីនិងភារកិច្ចបន្ថែមគឺ ប្រមូលប្រាក់ពន្ធសរុបរបស់អ្នកជាប់ពន្ធនិងបង់ប្រាក់ពន្ធទៅរតនាគារជាតិឬធនាគារចុះបញ្ជីគណនេយ្យនិងគ្រប់គ្រងស្ថិតិគ្រប់ប្រភេទពន្ធ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដ៏ទៃ និងសាខាពន្ធដារខណ្ឌត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធទាំងនោះ ត្រូវសុំគោលការណ៍ពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារដើម្បីរួមគ្នាដោះស្រាយ។

### ៣.១.២ គោលនយោបាយ

គោលនយោបាយពន្ធដារតាមសាខានីមួយៗ សំដៅលើការយកពន្ធនិងវិធីរកចំណូលផ្សេងៗទៀត និងការចំណាយរបស់រដ្ឋ ដោយបែងចែកធនធានសេដ្ឋកិច្ច ក្នុងគោលបំណងជំរុញរបស់មានកំណើនសេដ្ឋកិច្ចប្រកបដោយជីវភាព និងសម្បុរសធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោយបាយសារពើពន្ធ រដ្ឋត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចជា៖

១. ប្រសិទ្ធភាពនៃការគ្រប់គ្រង និងកៀរគរចំណូល
២. ការធ្វើវិចារណៈកម្មចំណាយគឺបែងចែកចំណាយថវិការដ្ឋរវាងការប្រើប្រាស់ និងការវិនិយោគសាធារណៈឱ្យបានសមស្រប។

គោលនយោបាយសារពើពន្ធរបស់ប្រទេសនីមួយៗ គួរតែមានគោលដៅជាគោលការណ៍ចំនួនបួនគឺការបែងចែកធនធាន ស្ថេរភាពវូបនីយកម្មកំណើន ការបែងចែកនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យស្មើគ្នា ។ តាមរយៈពន្ធ និងចំណាយសារធារណៈ រដ្ឋាភិបាលដើរតួនាទីសំខាន់ក្នុងការបែងចែកបណ្តាធនធាននៅក្នុងសេដ្ឋកិច្ច និងជំរុញខ្សែសង្វាក់ផលិតកម្មឱ្យកើនឡើង។

### ៣.១.៣ បេសកកម្ម និងទស្សនៈវិស័យ

បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ គឺដើម្បីជួយពន្លឿននិងសម្រួលដល់ការធ្វើធុរកិច្ចស្របច្បាប់ និងបង្កើតចំណូលថវិកាជាតិ ការធានាឱ្យមានការប្រកួតប្រជែងសេដ្ឋកិច្ច ប្រកបដោយសីល៍ធម៌ ការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពសង្គម និងសន្តិសុខជាតិ និងការធ្វើឱ្យមាននិរន្តភាពនៃការអភិវឌ្ឍន៍ និងសម្រេចបានតាមគោលដៅកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ អគ្គនាយកដ្ឋានពន្ធដារ មានបេសកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនាន
- អនុវត្តកម្មវិធីចាប់បង្ខំដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងរ៉ឹង និងអនុវត្តទោសទណ្ឌ តាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។
- ប្រមូលចំណូលពន្ធតាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ។
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ។
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ។
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ។
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួន ធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ។
- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយកិច្ចដំណើរការការងារនិង ប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងារខ្លួន។

ទស្សនវិស័យរបស់ពន្ធដារ គឺការអភិវឌ្ឍនខ្លួនឱ្យក្លាយជារដ្ឋបាលសារពើពន្ធ មួយស្របតាម បមាណីយ និងឧត្តមានុវត្តន៍ ជាអន្តរជាតិដោយមានការទទួលស្គាល់ពីថ្នាក់ជាតិ និងអន្តរជាតិលើ ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល និងកិច្ចប្រតិបត្តិការ ព្រមទាំងជាស្ថាប័នផ្តល់សេវាយ៉ាងមាន ប្រសិទ្ធភាពដល់សហគមន៍ធុរកិច្ចនិងភាគីពាក់ព័ន្ធ។

### ៣.១.៤ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

តួនាទីរបស់ពន្ធដារមាន ៣ គឺៈ

- ជាប្រភពចំណូលដ៏សំខាន់សម្រាប់ថវិកាជាតិ
- ជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ
- ទប់ស្កាត់ការនាំចូល ការនាំចេញ និងរក្សាតុល្យភាពចំណូលរបស់ប្រជាពលរដ្ឋ។

+ ភារកិច្ចពន្ធដារមានជាអាទិ៍ភាពដូចតទៅៈ

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិធម៌ការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេតនិងផ្ទុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ ប្រភេទនៃធ្វើសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ



ប្រកាសស្តីពីសវនកម្មពន្ធដារ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវនីតិវិធីនៃការធ្វើសវនកម្ម ដើម្បីធានានូវតម្លាភាពក្នុងការបង់ ពន្ធ និងបង្កើតបរិយាកាសប្រកួតប្រជែងដោយស្មើភាពក្នុងការប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។ មានគោលដៅកំណត់នូវវិធាននិងនីតិវិធី ព្រមទាំងសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋ

បាលសារពើពន្ធនិងអ្នក ជាប់ពន្ធ ពាក់ព័ន្ធនឹងការធ្វើសវនកម្មពន្ធដារ។ មានវិសាលភាពអនុវត្តលើអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សវកម្មពន្ធដារ សំដៅដល់ការពិនិត្យបញ្ជាក់លើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ទ្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធបានត្រឹមត្រូវ តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មពន្ធដារគឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រង និងប្រមូលពន្ធឲ្យមាន តម្លាភាព និងប្រសិទ្ធភាព ដើម្បីធានាសមធម៌ក្នុងការបង់ពន្ធ។ដោយយោងតាមប្រកាស២៧០ ដែលបានចេញនៅក្នុងថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៩ គេអាចចែកប្រភេទនៃសវនកម្មពន្ធដារជា២គឺ

**១.សវនកម្មលើលិខិតស្នាម**

សវនកម្មលើលិខិតស្នាម ត្រូវបានធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ។ ការធ្វើសវនកម្មលើលិខិតស្នាម គឺជាការ ពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធ ដែលមានភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នារវាងលិខិតប្រកាសសារពើពន្ធ ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងការ ប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ ។ ជាទូទៅសវកម្មនេះ ត្រូវផ្តោតសំខាន់ទៅលើ ចំណុចមិនប្រក្រតីច្បាស់លាស់នឹងងាយស្រួលដោះស្រាយដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ ដូចជាការផ្ទៀងផ្ទាត់លិខិតប្រកាសពន្ធ ជាមួយនឹងព័ត៌មានដែលរដ្ឋបាលសារពើពន្ធទទួលបានពីប្រភពផ្សេងៗជាដើម។ ក្នុងនោះរដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធមកបំភ្លឺនិងបង្ហាញឯកសារទាក់ទិននឹងភាពមិនប្រក្រតីដែលបានរកឃើញលើ លិខិតប្រកាសសារពើពន្ធ។ ក្នុងករណីដែលហានិភ័យទាំងឡាយដែលរកឃើញមានលក្ខណៈស្មុគស្មាញជាប្រព័ន្ធ ឬអាន ហានិភ័យខ្ពស់ ការធ្វើសវនកម្មលើលិខិតស្នាមត្រូវបញ្ឈប់និងផ្ទេរនៅជាការធ្វើសវនកម្មដល់ទីកន្លែងវិញ។ សវកម្មប្រភេទ នេះត្រូវធ្វើក្នុងអំឡុងពេល ១២ ខែ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

**២.សវនកម្មដល់ទីកន្លែង**

សវនកម្មដល់ទីកន្លែង គឺជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាសដែលជាកម្មវត្ថុនៃការ ធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្តែង បញ្ជីគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។ សវនកម្មប្រភេទនេះចែកចេញជា២ រួមមាន៖

ក. **សវនកម្មមានកម្រិត** គឺជាការធ្វើសវនកម្មរយៈពេលខ្លីនិងភ្លាមៗទៅលើប្រភេទពន្ធអាករមួយចំនួនជាអាទិ៍មាន អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែមរួមទាំងការបង្វិលសង និង ពន្ធអាករផ្សេងទៀតវៀរលែងតែពន្ធលើប្រាក់ចំណូល ដោយពិនិត្យទៅលើចំណុចដែលជាហានិភ័យទាំងឡាយក្នុងបញ្ជី គណនេយ្យ និងឯកសារពាក់ព័ន្ធ។ សវនកម្មនេះអាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត (N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត (N-1)។

ខ. **សវនកម្មពេញលេញ** គឺជាការធ្វើសវនកម្មលើពន្ធអាករគ្រប់ប្រភេទ និងវាយតម្លៃលើការកាន់កាប់បញ្ជីគណនេយ្យ របស់សហគ្រាស អោយត្រូវធ្វើការត្រួតពិនិត្យជាក់ស្តែងលើប្រតិបត្តិការអាជីវកម្ម ផ្ទៀងផ្ទាត់ទៅនឹងបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្ម ដើម្បីធានាបានថាគ្រាសបានរៀបចំរបាយការណ៍ គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវតាមច្បាប់ជាធរមាន និង

បានបំពេញភាពពពួកិច្ចបង់ពន្ធត្រឹមត្រូវតាម ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មនេះអាចធ្វើឡើងក្នុងរង្វង់ ៣ឆ្នាំជាប់ពន្ធថយក្រោយ (N-3) ប៉ុណ្ណោះ។ ក្នុងករណី មានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ឬមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេល ជាប់ពន្ធមុន ដែលតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញលើសពី៣ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាច ធ្វើឡើងក្នុងរង្វង់៥ឆ្នាំជាប់ពន្ធថយក្រោយ។ ក្នុងករណីចាំបាច់នឹងមានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ដែលតម្រូវឲ្យ មានការធ្វើសវនកម្មពេញលើសពី៥ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាចអ្វីឡើងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសាពើពន្ធដោយត្រូវស្នើសុំការអនុញ្ញាតធ្វើសវនកម្ម ជាមុនពីរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើករណីជាក់ស្តែងនីមួយៗ។

- វៀរលែងតែក្នុងករណីមានភស្តុតាងច្បាស់លាស់ មូលដ្ឋានគិតពន្ធតែមួយ ប្រភេទពន្ធតែមួយ ដែលបានធ្វើការ កំណត់ពន្ធរួចហើយមិនត្រូវជាកម្មវត្ថុនៃការធ្វើសវនកម្មជាថ្មីម្តងទៀតទេ។
- វៀរលែងតែក្នុងករណីដូចខាងក្រោម ការធ្វើសវនកម្មដូចមានចែងក្នុងប្រការនេះ មិនតម្រូវឲ្យធ្វើលើគ្រប់ឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធទេ គឺត្រូវធ្វើឡើងតែចំពោះឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធណាដែលមានហានិភ័យដល់ចំណូលពន្ធតែប៉ុណ្ណោះ៖

  ១. មានការស្នើសុំពីអ្នកជាប់ពន្ធ

  ២. សហគ្រាសដែលមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធមុន

  ៣. មានភស្តុតាងថាសហគ្រាសបានគេចវេះពន្ធ។

ក្នុងករណីដែលរកឃើញជាយថាហេតុនូវភស្តុតាង ឬបទល្មើសជាក់ស្តែងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធ ដែលកើតមានឡើងដោយចេតនារៀបចំរបស់សហគ្រាស អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារអាចចាត់ឱ្យអង្គភាពណាមួយ ធ្វើសវនកម្មពិសេស ឬធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទៅលើសហគ្រាស។ ក្នុងការលើនេះ អង្គភាពដែលកំពុងធ្វើសវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត ឬសវនកម្មពេញលេញ ត្រូវបញ្ឈប់នឹងដកចេញ ពីកម្មវិធីសវនកម្មរបស់ខ្លួន ហើយប្រសិនបើការស៊ើបអង្កេតបទល្មើសពន្ធដារមិនឈានដល់ការប្តឹងចោទទៅតុលាការ អង្គភាពដែលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបង្វែរ ករណីនេះទៅអង្គភាពពាក់ព័ន្ធដើម្បីបន្តនីតិវិធីសវនកម្មវិញ។

## ៣.៣ នីតិវិធីនៃការធ្វើសវនកម្មពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ

### ក. ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម

ការជ្រើសរើសសហគ្រាសធ្វើសវនកម្មត្រូវធ្វើឡើងដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ការវិភាគហានិភ័យ
- បទផលបានមកពីការផ្ទៀងផ្ទាត់ផ្លូវផ្តងព័ត៌មាន (Crosscheck)
- ព័ត៌មានទទួលបានពីតតិយជន
- ព័ត៌មានអំពីប្រភេទពន្ធឬវិស័យជាក់លាក់ណាមួយ
- ព័ត៌មានរបស់ក្រុមអ្នកជាប់ពន្ធណាមួយ

- ទីតាំងរបស់សហគ្រាស។ល។

**ខ. ការរៀបចំកម្មវិធីសវនកម្ម**

ដើម្បីចៀសវាងការធ្វើសវកម្មត្រួតជាន់គ្នា អគ្គនាយកដ្ឋានពន្ធដារត្រូវបង្កើតគណៈកម្មការរៀបចំបែងចែកសហគ្រាស មួយដែលមានភារកិច្ចរៀបចំបញ្ជីឈ្មោះនឹងចំនួនសហគ្រាស ដើម្បីបែងចែកសម្រាប់ការធ្វើសវនកម្មលើលិខិតស្នាម សវនកម្ម មានកម្រិត និងសវនកម្មពេញលេញ សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ។ សមាសភាពនៃគណៈកម្មការនេះ ត្រូវកំណត់ដោយ លិខិតបង្គាប់ការរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ក្រោយពីបានទទួយការបែងចែកចំនួនសហគ្រាស នាយកដ្ឋានសវនកម្មសហគ្រាស នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសារខាពន្ធដារខេត្ត-ខណ្ឌ ត្រូវជ្រើសរើសសហគ្រាសសម្រាប់ធ្វើសវនកម្មដោយផ្អែកលើលក្ខណវិនិច្ឆ័យដែលបានកំណត់ក្នុងប្រការ៧ នៃប្រការនេះនិងរៀបចំកម្មវិធីនិងផែនការសវនកម្មទៅតាមប្រភេទនៃសវនកម្មនីមួយៗឱ្យបានច្បាស់លាស់ តាមសមត្ថកិច្ចរៀងៗខ្លួន ហើយត្រូវផ្ញើមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារធ្វើការពិនិត្យសម្រេច។ដើម្បីជានានូវនិរន្តរភាពនៃការធ្វើសវនកម្ម គណៈកម្មការរៀបចំបែងចែកសហគ្រាសសម្រាប់ធ្វើសវនកម្មពន្ធដារត្រូវ រៀបចំបញ្ជីឈ្មោះសហគ្រាសសម្រាប់ធ្វើសវនកម្មឱ្យបានមុនខែមករា នៃឆ្នាំផែនការសវនកម្ម។ អង្គភាពដែលមានភារកិច្ច ធ្វើសវនកម្មត្រូវរៀបចំអនុវត្តកម្មវិធីសវមកម្មឲ្យរួចរាល់ស្រេចបាច់នៅដំណាច់ឆ្នាំនៃផែនការសវនកម្ម ឬយ៉ាងយឺតចំផុត នៅដំណាច់ត្រីមាសទី ១ នៃឆ្នាំបន្ទាប់។ ក្នុងករណីមិនអាចរកឃើញថាអ្នកជាប់ពន្ធមិនបានធ្វេសប្រហែសឬធ្វេសប្រហែសធ្ងន់ធ្ងរទេ សវនករពន្ធដារដែលធ្វើសវនកម្មត្រូវសរុបលទ្ធផលនឹងបិទបញ្ចប់ការធ្វើសវនកម្មរបស់ខ្លួន។ ក្នុងករណីចាំបាច់ ដែលមិនអាចបិទបញ្ចប់ការធ្វើសវនកម្មបាន ប្រធានអង្គភាពត្រូវស្នើសុំការសម្រេចពីអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់។ ក្នុងករណីពិសេសណាមួយ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អាចចាត់ឱ្យអង្គភាពមួយឬច្រើនចុះធ្វើសវនកម្ម រួមគ្នាលើសហគ្រាស។

**គ.ការជូនដំណឹងស្តីពីការធ្វើសវនកម្ម**

១.មុនពេលចាប់ផ្តើមសវនកម្ម រដ្ឋបាលសារពើពន្ធត្រូវជូនដំណឹងស្តីពីការធ្វើសវនកម្មដល់អ្នកជាប់ពន្ធ ឬតំណាងអ្នក ជាប់ពន្ធជាមុន។ លិខិតជូនដំណើងត្រូវមានសេចក្តីបញ្ជាក់អំពី ៖

- ឈ្មោះ អាសយដ្ឋាន លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាស
- ការបរិច្ឆេទនៃការចុះធ្វើសវនកម្ម
- កាលិយបរិច្ឆេទ(រយៈពេលជាប់ពន្ធ ឬឆ្នាំជាប់ពន្ធ ដែលត្រូវធ្វើសវនកម្ម)
- ប្រភេទសវនកម្ម (សវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត ឬសវនកម្មពេញលេញ)។
- ឈ្មោះមន្ត្រីដែលទទួលភារកិច្ចធ្វើសវនកម្ម។

លិខិតជូនដំណឹងត្រូវភ្ជាប់មកជាមួយនូវបញ្ជីឯកសារឬលិខិតស្នាម ដែលត្រូវត្រៀមសម្រាប់ការធ្វើសវនកម្ម។

២.លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់ យ៉ាងត្រឹមត្រូវការពេលដែលបានប្រគល់ជូនអ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់

អ្នកជាប់ពន្ធ ទោះបីជាអ្នកជាប់ពន្ធដែលត្រូវបានជូនដំណឹងនោះ បដិសេធការប្រគល់ឬការទទួលលិខិអនុសិដ្ឋនេះក្តី។

៣.កាលបរិច្ឆេទនៃលិខិតជូនដំណឹង គឺជាកាលបរិច្ឆេទនៃការប្រគល់ជូនអ្នកជាប់ពន្ធ។ ក្នុងករណីលិខិតជូនដំណឹង ត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹងគឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ ការិយាល័យប្រៃសណីយ៍។

៤.ក្នុងករណីដែលអ្នកជាប់ពន្ធបានផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ហើយមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋានដែលអ្នកជាប់ពន្ធបាន ប្រកាសចុងក្រោយត្រូវចាត់ទុកថាបានប្រគល់ទទួល ត្រឹមត្រូវ។

៥.ក្នុងករណីដោយមូលហេតុណាមួយ ដែលលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធតាម តាមវិធីដូចមានចែងក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃប្រការនេះ លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារលើពន្ធបាន៖

- បិទលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋានទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ
- ផ្សព្វផ្សាយតាមសារព័ត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឲ្យលើសពី ១៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

៦.សវនកម្មអាចត្រូវបានចាប់ផ្តើម ១០ថ្ងៃ នៃថ្ងៃធ្វើការ ឬក្រោយពីការប្រគល់លិខិតជូនដំណឹងស្តីពីការធ្វើសវនកម្ម ដល់អ្នកជាប់ពន្ធ ឬឆាប់ជាងនេះដោយយោងតាមសំណើរបស់អ្នកជាប់ពន្ធ។ ក្នុងករណីពិសេសដោយផ្អែកតាមមាត្រា១០០ និងមាត្រា១១៦ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធអាចចុះធ្វើសវនកម្មដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អ្នកជាប់ពន្ធ។

៧.ក្នុងករណីដែលមានឯកសារគ្រប់គ្រាន់ រយៈពេលសវនកម្មត្រូវបានកំណត់យ៉ាងយូរបំផុត ០៣ ខែសម្រាប់សវនកម្មលើលិខិតស្នាមនិងសវកម្មមានកម្រិតនិងរយៈពេល ០៦ ខែសម្រាប់សវនកម្មពេញលេញ។

**ឃ. ការស្នើសុំពន្យាពេលធ្វើសវនកម្ម**

ក្នុងករណីមិនអាចទទួលការធ្វើសវនកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ អ្នកជាប់ពន្ធអាចស្នើសុំពន្យារ ពេលចុះធ្វើសវនកម្មដោយផ្អែកលើមូលហេតុសមស្រប ដោយមិនឱ្យលើសពី ៣០ថ្ងៃ ក្រោយថ្ងៃត្រូវចុះធ្វើសវនកម្មដែលមានចែងក្នុងលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មឡើយ។ ក្នុងករណីរយៈពេលស្នើសុំតិចជាង ១០ថ្ងៃ អ្នកជាប់ពន្ធអាចធ្វើ ឡើងដោយផ្ទាល់មាត់មកសវនករពន្ធដារ។ ក្នុងករណីរយៈពេលស្នើសុំចាប់ពី ១០ថ្ងៃ ដល់ ៣០ថ្ងៃ អ្នកជាប់ពន្ធត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកប្រធាននាយកដ្ឋាន ឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ។

### ង. ឯកសារតម្រូវសម្រាប់ការធ្វើសវនកម្ម

ក្រោយពីបានទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវត្រៀមឯកសារពាក់ព័ន្ធនឹងអាជីវកម្ម ទាំងអស់ដើម្បីទុកផ្តល់ឲ្យសវនករពន្ធដារក្នុងករណីមានការស្នើសុំ។ ឯកសារដែលត្រូវត្រៀមជាអាទិ៍មានៈ

១. ព័ត៌មានសហគ្រាសៈ

- រចនាសម្ព័ន្ធគ្រប់គ្រង
- វិញ្ញាបនប័ត្រចុះបញ្ជី
- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (អតប)
- លក្ខន្តិកៈ
- វិញ្ញាបនប័ត្រផ្សេងៗ សម្រាប់ធ្វើសកម្មភាពអាជីវកម្មពីអាជ្ញាធរផ្សេងៗ ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទេសចរណ៍ ជាដើម។ល។

២. ឯកសារគណនេយ្យៈ

- របាយការណ៍ហិរញ្ញវត្ថុ
- តារាងលម្អិតគណនីនីមួយៗនៃទ្រព្យសកម្ម
- តារាងលម្អិតគណនីនីមួយៗនៃទុនម្ចាស់ទ្រព្យនឹងបំណុល
- តារាងលម្អិតគណនីនីមួយៗនៃរបាយការណ៍លទ្ធផល (ចំណេញ/ខាត)

\+ សក្ខីបត្រដើមនៃឯកសារផ្សេងៗ ៖

- តារាងបើកប្រាក់បៀវត្សប្រចាំខែ
- កិច្ចសន្យាការងាររបស់បុគ្គលិកបរទេសនិងថ្នាក់គ្រប់គ្រង
- កិច្ចសន្យាជួលឬលក់ផ្សេងៗ
- កិច្ចសន្យាដេញថ្លៃផ្សេងៗ បើមាន
- លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ
- ទិនានុប្បវត្តិទិញ- លក់ប្រចាំខែ
- តារាងកែតម្រូវការគណនាប្រាក់ពន្ធ
- វិក្កយបត្រទិញ-លក់។ល។

ក្នុងពេលធ្វើសវនកម្ម ប្រសិនបើពិនិត្យឃើញថាមានឯកសារមួយចំនួនដែលមានការចាំបាច់សម្រាប់ប្រើប្រាស់ជា មូលដ្ឋានក្នុងការកំណត់ពន្ធ សវនករអាចធ្វើការថតចម្លងឬស្នើសុំឱ្យអ្នកជាប់ពន្ធផ្តល់ឲ្យត្រូវឯកសារទាំងនោះ។ អ្នកជាប់ពន្ធ ត្រូវផ្តល់ឯកសារដែលបានស្នើសុំយ៉ាងយឺតបំផុត ៧ ថ្ងៃ ក្រោយការស្នើសុំ។ ការខកខានមិនបានផ្តល់ឯកសារដែលបាន ស្នើសុំ សវនករពន្ធដារអាចធ្វើការកំណត់ពន្ធដោយផ្អែកលើព័ត៌មានដែលសវនករពន្ធដារមានស្របតាមច្បាប់និងបទប្បញ្ញត្តិ ស្តីពីពន្ធដារ។

## ច. សិទ្ធិប្រមូលព័ត៌មាន

១. យោងតាមច្បាប់នឹងបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់ ឬដើម្បីប្រមូលពន្ធ រដ្ឋបាល សារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជនឲ្យ៖

- ផ្តល់ព័ត៌មានដែលទាក់ទិននឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ ឬឯកសារសារពាក់ព័ន្ធដទៃទៀត

- បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងដើម្បីផ្តល់ព័ត៌មាន និងដើម្បីបង្ហាញឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

២.សម្រាប់ការធ្វើសវនកម្មនីមួយៗ រដ្ឋបាលសារពើពន្ធ មានសិទ្ធិចូលគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុក ជាគ្រឹះស្ថានអាជីវកម្ម ឬជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់ បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ នៅក្នុងពេលប្រកបអាជីវកម្ម ឬគ្រប់ពេលទាំងអស់ក្នុងករណី ឬគ្រប់ពេលទាំងអស់ក្នុងករណីបានដីកាដែលព្រះរាជអាជ្ញា ឬចៅក្រមបានចេញឱ្យ។

៣.រដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែងដូច ដែលមានចែងខាងលើអាច៖

- ធ្វើសម្រង់ ឬចម្លងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងទាំងនោះ
- រឹបអូសឯកសារនានាឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មានសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសំគាល់ ឃាត់ទុកទំនិញ បើសិនជាមានជាប់ទាក់ទងដល់ការអនុវត្តពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុជាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និង ស្តុកដទៃទៀត។

៤. សវនករពន្ធដារអាចទាមទារឱ្យអ្នកជាប់ពន្ធផ្តល់ឯកសារផ្សេងក្រៅពីឯកសារអាជីវកម្ម (ឧទាហរណ៍គណនីផ្ទាល់ខ្លួន នៅធនាគារ ការទិញ-លក់ទ្រព្យសម្បត្តិ ចំណាយផ្ទាល់ខ្លួន ឬ ចំណាយផ្សេងៗទៀត) ក្នុងករណីសហគ្រាសជាសហគ្រាស ឯកបុគ្គល។

៥. ក្នុងករណីដែលទីតាំងការងារដែលផ្តល់ដោយអ្នកជាប់ពន្ធមិនសមស្របសម្រាប់ធ្វើសវនកម្ម ឬមិនមានម៉ាស៊ីនថតចម្លង សវនករពន្ធដារអាចយកឯកសារទៅពិនិត្យនៅការិយាល័យរបស់ខ្លួន ដោយមានការឯកភាពពីអ្នកជាប់ពន្ធ។ ក្នុងករណីនេះឯកសារទាំងអស់ត្រូវប្រគល់ជូនអ្នកជាប់ពន្ធវិញនៅពេលដែលការធ្វើសវនកម្មត្រូវបានបញ្ចប់។ ឯកសារដែល ត្រូវប្រគល់ឱ្យអ្នកជាប់ពន្ធវិញ ត្រូវមានតារាងប្រគល់នឹងទទួលត្រឹមត្រូវ ។

៦. ក្នុងករណីឯកសារនឹងបញ្ជីគណនេយ្យបានរក្សាទុកជាទម្រង់អេឡិចត្រូនិក សហគ្រាសត្រូវមានឯកសារច្បាប់ដើមជា ក្រដាសស្នាមសម្រាប់ការត្រួតពិនិត្យ។ ប្រសិនបើនៅពេលត្រួតពិនិត្យ អ្នកជាប់ពន្ធមិន

អាចផ្តល់ឯកសារជាក្រដាសស្នាម អ្នកជាប់ពន្ធត្រូវអនុញ្ញាតឱ្យសវនករពន្ធដារត្រួតពិនិត្យប្រព័ន្ធកុំព្យូទ័រ និង ថតចម្លងឯកសារជាទម្រង់អេឡិចត្រូនិកតាមរយៈ ឧបករណ៍ថតចម្លង។

**ឆ. ការពិនិត្យឯកសារ**

អ្នកជាប់ពន្ធត្រូវផ្តល់ឯកសារសម្រាប់ការធ្វើសវនកម្មដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ តាមការម្រូវរបស់សវនករពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធមិនបានផ្តល់ឯកសារឬព័ត៌មានតាមការតម្រូវ សវនករពន្ធដារអាចធ្វើការកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមានដូចៈ

- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងៗដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ
- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសព័ត៌មាន
- ព័ត៌មានផ្សេងៗទៀតដែលរដ្ឋបាលសារពើពន្ធបានទទួល។

ប្រសិនបើប្រាក់ចំណូលជាប់ពន្ធឬប្រាក់ចំណូល ដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀប ទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានា ដែលធ្វើឲ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោ នោះសវនករពន្ធដារមានសិទ្ធិ កំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូល ប៉ាន់ស្មានសមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុ នានានោះ។ ការស្វែងរកភស្តុតាងនានាដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

**ជ. ការពន្យល់អំពីលទ្ធផលសវនកម្ម**

\+ ក្រោយការត្រួតពិនិត្យឯកសារ សវនករពន្ធដារត្រូវធ្វើការបូកសរុបលទ្ធផលសវនកម្មដោយត្រូវពន្យល់អ្នកជាប់ពន្ធអំពីៈ

- ការយល់ស្របឬមិនយល់ស្របនូវចំណែកណាមួយឬទាំងស្រុង នៃការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ
- ការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារដែលបានរកឃើញ
- មូលដ្ឋាននិងបទប្បញ្ញត្តិពន្ធដារពាក់ព័ន្ធដែលទាក់ទិននឹងការកំណត់ពន្ធ
- ប្រាក់ពន្ធដែលនឹងត្រូវកំណត់ឡើងវិញ។

\+ អ្នកជាប់ពន្ធ អាចធ្វើការបញ្ចេញយោបល់ ដែលក្នុងនោះអាចយល់ស្របឬជំទាស់នូវចំណែកណាមួយ ឬទាំងស្រុងនៃលទ្ធផលសវនកម្មដូចក្នុងកថាខណ្ឌ១ នៃប្រការនេះ ដោយត្រូវបង្ហាញឯកសារបន្ថែមដែលគាំទ្រដល់ការជំទាស់របស់ខ្លួន។

\+ ប្រសិនបើអ្នកជាប់ពន្ធពុំមានការអះអាងសមស្រប និង បង្ហាញនូវឯកសារគាំទ្រគ្រប់គ្រាន់ដល់ការជំទាស់របស់ខ្លួន សវនករពន្ធដារត្រូវបញ្ជាក់ជូនអ្នកជាប់ពន្ធអំពីការមិនឯកភាពលើការជំទាស់នោះ។

**ឈ. លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ**

- ក្រោយពីបញ្ចប់ការធ្វើសវនកម្ម សវនករពន្ធដារត្រូវធ្វើរបាយការណ៍អំពីលទ្ធផលសវនកម្ម ដែលក្នុងនោះអាច មានឬគ្មានទឹកប្រាក់កំណត់ពន្ធឡើងវិញ ហើយលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញត្រូវ

បានប្រគល់ជូនអ្នកជាប់ពន្ធឬអ្នកតំណាង ស្របតាមវិធានដូចបានចែងក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ កថាខណ្ឌ៤ និងកថាខណ្ឌ៥ នៃប្រកាស៩ នៃប្រកាសនេះ។

- ក្នុងករណីយល់ស្របតាមការកំណត់ពន្ធឡើងវិញរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ពន្ធបន្ថែមការប្រាក់ដែលបានកំណត់ តាមកាលបរិច្ឆេទនៃការជូនដំណឹងជាលាយល័ក្ខណអក្សរ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

- ក្នុងករណីមិនយល់ស្រប អ្នកជាប់ពន្ធមានរយៈពេល ៣០ ថ្ងៃ ដើម្បីឆ្លើយតបជាលាយល័ក្ខអក្សរចំពោះការកំណត់ ពន្ធឡើងវិញទៅអង្គភាពពន្ធដារដែលទទួលបន្ទុកធ្វើសវនកម្មនោះ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយកឬ ជំទាស់នូវចំណែកណាមួយឬទាំងស្រុងនៃការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថា យល់ព្រមចំពោះការ កំណត់ពន្ធឡើងវិញ បើសិនជាពុំបានឆ្លើយតប។

- អង្គភាពដែលបានកំណត់ពន្ធត្រូវរក្សាទុកពេលវេលាចំនួន ៣០ ថ្ងៃ មុននឹងបញ្ជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញទៅឱ្យអង្គភាពប្រមូលពន្ធ។ នៅពេលទទួលលិខិតជូនដំណឹងពីអង្គភាពកំណត់ពន្ធ អង្គភាពប្រមូលពន្ធត្រូវ កត់ត្រាជាបំណុលពន្ធត្រូវទារ និងត្រូវចេញលិខិតជូនដំណឹងស្តីពីការទារបំណុលពន្ធទៅអ្នកជាប់ពន្ធ។

### ៣. ការតវ៉ាចំពោះការកំណត់ពន្ធឡើងវិញ

អ្នកជាប់ពន្ធដែលមិនយល់ស្រប នូវចំណែកណាមួយឬទាំងស្រុងនៃការកំណត់ពន្ធដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌ៣ នៃប្រការ១៥ នៃប្រកាសនេះ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារក្នុងអំឡុងពេល ៣០ ថ្ងៃ ក្រោយពេលទទួលបានលិខិតជូនដំណឹងទារបំណុលពន្ធ ដោយភ្ជាប់មកជាមួយ ត្រូវលិខិតដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធ និងភស្តុតាងនានាដែលបញ្ជាក់ថាការកំណត់ពន្ធមិនត្រឹមត្រូវ។ វិធាននិង នីតិវិធីនៃការតវ៉ាត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ១៤៧០ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។

### ជ. ពន្ធបន្ថែម និងការប្រាក់

ចំពោះការកំណត់ពន្ធឡើងវិញ ពន្ធបន្ថែម និងការប្រាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

- ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនតិចជាងឬស្មើ ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានធ្វេសប្រហែស និងត្រូវទទួលរងពន្ធបន្ថែម ១០% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែម ការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

- ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនលើសពី ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានធ្វេសប្រហែសធ្ងន់ធ្ងរ និងត្រូវទទួលរងពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

- ក្នុងករណីដែលអ្នកជាប់ពន្ធគ្មានបញ្ជិកាគណនេយ្យ ឬកាន់បញ្ជីគណនេយ្យក្លែងបន្លំ ឬមិនសហការផ្តល់ឯកសារនានាទាក់ទិននឹងការធ្វើសវនកម្មអ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានគេចវេះពន្ធ និងត្រូវទទួលរងពន្ធ ៤០% នៃប្រាក់ពន្ធដែលខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។ក្រៅពីពន្ធបន្ថែមនិងការប្រាក់ដូចមានចែងក្នុងកថាខណ្ឌ១ កថាខណ្ឌ២ និងកថាខណ្ឌ៣ នៃប្រការនេះ អ្នកជាប់ពន្ធ ត្រូវទទួលរងទោសទណ្ឌដទៃទៀតស្របតាមច្បាប់នឹងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ឋ. កាតព្វកិច្ចរបស់សវនករពន្ធដារនៅពេលចុះធ្វើសវនកម្ម**

នៅពេលចុះធ្វើសវនកម្មពន្ធដារត្រូវបង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយអគ្គនាយកនៃនាយកដ្ឋានពន្ធដារ ឬតំណាងដែលបានទទួលសិទ្ធិ និងត្រូវពន្យល់អ្នកជាប់ពន្ធឱ្យបានច្បាស់លាស់អំពីសិទ្ធិនិងកាតព្វកិច្ច របស់រដ្ឋបាលសារពើពន្ធក្នុងការធ្វើសវកម្ម នីតិវិធីនៃការធ្វើសវនកម្ម និងសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធដែលទទួល រងការធ្វើសវនកម្មពន្ធដារ ដោយអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។

**ឌ. សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ**

ក្នុងអំឡុងពេលធ្វើសវនកម្ម អ្នកជាប់ពន្ធមានសិទ្ធិនិងកាតព្វកិច្ច ដូចខាងក្រោម÷

- សិទ្ធិជ្រើសរើសតំណាងស្របច្បាប់ដោយមានការបញ្ជាក់ជាលាយលក្ខណអក្សរ
- សិទ្ធិទទួលបានការពន្យល់អំពីច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនានា
- សិទ្ធិទទួលបានការពន្យល់អំពីហេតុផលនឹងមូលដ្ឋាននៃការកំណត់ពន្ធឡើងវិញ
- ត្រូវផ្តល់ឯកសារតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ
- ត្រូវបង្ហាញខ្លួនតាមកាលបរិច្ឆេទនិងទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

**ឍ. ការតវ៉ាចំពោះការប្រព្រឹត្តខុសឆ្គងនឹងនីតិវិធីសវនកម្មរបស់សវនករ**

ក្នុងករណីសវនករពន្ធដារមិនគោរពតាមវិធាននិងនីតិវិធីដូចមានចែងក្នុងប្រកាសនេះ អ្នកជាប់ពន្ធអាចតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជាធម្មតាការវិភាគចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់តែងតែមាន។ ការវាយតម្លៃពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យយើងដឹងពីចំណុចខ្លាំងចំណុចខ្សោយសម្រាប់យកកែលម្អឱ្យកាន់តែល្អប្រសើរ និងកាន់តែច្បាស់លាស់ក្នុងការអនុវត្តជាក់ស្តែងក៏ដូចជាការគ្រប់គ្រងផងដែរ។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការធ្វើសវនកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ ស្តីពីការសវនកម្មរួចមកខ្ញុំបាទបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយ មួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

១. ការធ្វើសវនកម្មពន្ធដារ ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការប្រមូលពន្ធនេះសម្រាប់ចូលថវិកាជាតិ វាបានចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន និងវត្តអារាមជាដើម។ ទោះរីករាលដាលនៃជំងឺកូវីដ-១៩ នៅដើមឆ្នាំ ២០២០ គួបផ្សំនឹងភាពមិនប្រាកដប្រជា នៃស្ថានភាពសេដ្ឋកិច្ចសកលនៅឆ្នាំ២០២២ដែលបណ្តាលមកពីសង្គ្រាមរវាងប្រទេស រុស្ស៊ីនិងអ៊ុយក្រែន ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ នៃប្រទេសមហាអំណាច និងការកើនឡើងសម្ពាធអតិផរណា ក៏បានជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ផងដែរ។ ទោះស្ថិតក្នុងបរិការណ៍ដ៏លំបាកនេះក្តី សម្រាប់ឆ្នាំ២០២៣ ស្ថានភាព សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករចុងក្រោយថានឹងងើបឡើងវិញ ហើយរំពឹងថានឹង សម្រេចបានកំណើនរង្វង់ ៥,៦%។ ជាមួយគ្នានេះ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការ គ្រប់គ្រងឆ្នាំ២០២៣ បានកំណត់ផែនការចំណូលសារពើពន្ធក្នុងស្រុក ចំនួន ១៤ ៦៤៥,៣៨ ប៊ីលានរៀល (ប្រមាណ ៣ ៥៧១,៦៩ លានដុល្លារ) បើធៀបនឹងផែនការចំណូលសារពើពន្ធក្នុងស្រុកនៃ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ កើនឡើង ២៦,៧%ហើយកត្តាទាំងនេះ វាបានចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិជាច្រើន

២. ការដកហូតពន្ធតាមសហគ្រាសស្របតាមមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិដែលបានចែងច្បាស់លាស់តាមប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

៣. មានកិច្ចសហការល្អជាមួយមន្ត្រីក្នុងអង្គភាព និងស្ថាប័នពាក់ព័ន្ធមួយចំនួនធំ

៤. បានផ្តល់ជូននូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំចំណេះដឹង ការពន្យល់ណែនាំដែលទាក់ទងនឹងការបង់ពន្ធផ្សេងៗ ដែលធ្វើឱ្យអ្នកជាប់ពន្ធយល់កាន់តែច្បាស់ និងពេញចិត្តបង់ពន្ធដោយភាពស្មោះត្រង់

៥. ការអនុវត្តន៍កម្មវិធីចាប់បង្ខំគោលការណ៍យុត្តធម៌ និងបទបញ្ញត្តិនានា ដោយមានប្រសិទ្ធភាព និងមានភាពស្មើគ្នាចំពោះអ្នកជាប់ពន្ធ (អ្នកជាប់ពន្ធតូច មធ្យម និងធំ)

៦. ផ្តល់សេវា និងការអប់រំនានាដល់អ្នកដកហូតពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារ ត្រូវបានអនុវត្តបានយ៉ាងត្រឹមត្រូវ

៧. អត្រាលម្អៀងលើប្រាក់ពន្ធតាមថ្នាក់នីមួយៗនៃការគិតពន្ធ មានភាពសមស្រប មានន័យថា ទឹកប្រាក់បង់ពន្ធតិច ឬច្រើនគឺអាស្រ័យតាមចំណូលអង្គភាពនីមួយៗ
៨. ការផ្តល់សិទ្ធិដល់អ្នកជាប់ពន្ធ ក្នុងការដាក់ពាក្យតវ៉ា រាល់ការមានកំហុសដោយអចេតនាលើការគណនាលេខផ្សេងៗ ចំពោះការដាក់លិខិតប្រកាសពន្ធ
៩. សវនកម្មពន្ធដារបានជួយប្រជាជនតាមលក្ខណៈប្រយោលដូចជា ផ្តល់ជាប្រាក់របស់របរប្រើប្រាស់ ឬ ជាស្បៀងអាហារ ក្នុងពេលដែលវីរុសកូវីត១៩ បានចូលមកក្នុងប្រទេស។
១០.រាល់ការបង់ពន្ធមានភាពយឺតយ៉ាវ តម្រូវឱ្យបង់ប្រាក់ពន្ធបន្ថែមលើទឹកប្រាក់ ដែលត្រូវបង់តាមអត្រាដែលបានកំណត់សម្រាប់ការខកខានក្នុងខែ និងពិន័យការប្រាក់បន្ថែមទៀតប្រសិនបើឈានដល់ខែបន្ទាប់។ នេះជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រជាច្រើន ក្នុងការប្រមូលពន្ធ ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។
១១.មានបទបង្ហាញច្បាស់លាស់ និងមានសិក្ខាសាលាក្នុងការបង្ហាញច្បាប់ថ្មីស្តីពីសវនកម្មពន្ធដារដែលមានភាពងាយស្រួលដល់អ្នកជាប់ពន្ធថ្មី និងចាស់អាចយល់ដឹងបន្ថែម។
១២.ពន្ធដារបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ ដែលបានជួយសម្រួលដល់ការដាក់លិខិតប្រកាសពន្ធផ្សេងៗ ចំណេញពេលវេលា និងពន្ធដារបានប្រមូលពន្ធបានឆាប់រហ័ស និងប្រសិទ្ធិភាពខ្ពស់ ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងការរកឃើញចំណុចខ្លាំងមួយចំនួនខាងលើ ពួកយើងក៏បានរកឃើញចំណុចអសកម្មមួយចំនួនផងដែរ ដែរបានរារាំងក៏ដូចជាផ្តល់ផលប៉ះពាល់ដល់ការធ្វើសវនកម្ម។ ចំណុចខ្សោយទាំងនោះ មានដូចខាងក្រោមគឺ៖

១. សវនកម្មពន្ធដារគឺជាការខាតបង់ប្រាក់មួយផ្នែកតូចរបស់អង្គភាពដែលប្រកបរបរអាជីវកម្ម បណ្តាលឱ្យអ្នកជាប់ពន្ធខ្លះដែលមិនទាន់យល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួននោះ មានភាពមិន ពេញចិត្តក្នុងការបង់ពន្ធជូនរដ្ឋ
២. មន្ត្រីដកហូតពន្ធមួយចំនួនតូចមានសកម្មភាព និងសម្តែងនូវឥរិយាបថមិនសូវសមរម្យ ដែលជាហេតុនាំឱ្យប៉ះពាល់ដល់កិត្តិនាមរបស់អគ្គនាយកដ្ឋានពន្ធដារ
៣. ទម្លាប់នៃការបង់ប្រាក់ដោយបុគ្គល សម្រាប់ការសម្របសម្រួលការងារទៅឱ្យមន្ត្រីសាធារណៈ
៤. មិនទទួលបានកិច្ចសហការពីស្ថាប័នពាក់ព័ន្ធមួយចំនួនតូច
៥. ចំនួនមន្ត្រីមានតិច ធៀបទៅនឹងសហគ្រាសដែលមានច្រើន និងកំពុងបង្កើតថ្មីបន្ថែមជារៀងរាល់ថ្ងៃ
៦. ទោះបីមន្ត្រីពន្ធដារខិតខំរឹតបន្តឹង ទប់ស្កាត់ទៅលើការគេចវេសពន្ធយ៉ាងណាក៏ដោយ ក៏នៅមានចំណុចធ្វេសប្រហែសមួយចំនួនដូចជា ការគេចវេសមិនបង់ពន្ធ ការពន្យាពេលការបង់ពន្ធ និងការបង់ពន្ធមិនត្រឹមត្រូវតាមច្បាប់

៧. ពន្ធដារមិនបានត្រួតពិនិត្យគ្រប់ជ្រុងជ្រោយ លើពាក្យតវ៉ារបស់អ្នកជាប់ពន្ធមួយចំនួនតូច ហេតុនេះ ហើយវាធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការបង់ពន្ធ រហូតអាចឈានដល់មានការដាក់ពាក្យបណ្តឹងតវ៉ាតាមផ្លូវច្បាប់

៨. គណនេយ្យករមួយចំនួនតូចមិនទាន់យល់ច្បាស់ពី ការប្រកាសពន្ធអាជីវកម្មតាមអនឡាញ ការប្រកាសពន្ធអាជីវកម្មតាមអនឡាញ ដោយសារអគ្គនាយកដ្ឋានពន្ធដារទើបតែដាក់ឱ្យប្រើប្រាស់នៅដើមឆ្នាំ ២០២១។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ សវនកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ រួចមក ធ្វើឱ្យយើងអាចសន្និដ្ឋានបានថាដំណើរការនៃធ្វើសវនកម្ម គឺជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការបង្កើននូវចំណូលប្រសិទ្ធភាព ការគោរពកាតព្វកិច្ច និងជួយបង្កើនថវិកាជាតិ តាមរយៈពីបុគ្គលជាប់ពន្ធតូច មធ្យម និង ធំ និងតាមរយៈប្រភពចំណូលកម្ពុជា និងប្រភពបរទេស ដែលរដ្ឋប្រមូលបានប្រាក់ចំណូលខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ។ម៉្យាងវិញទៀត អាចឱ្យយើងយល់ដឹងបន្ថែមពីការពិនិត្យបញ្ជាក់លើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធ បានត្រឹមត្រូវ តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ព្រមទាំងវិធីសាស្ត្រ ក្នុងការធ្វើសវនកម្ម យល់ដឹងពីទ្រឹស្តី នៃប្រភេទពន្ធទូទៅជាពិសេសសវនកម្មពន្ធដារ ដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់ ដើម្បីឱ្យអ្នកជាប់ពន្ធកាន់តែយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ពន្ធផងដែរ។

ការប្រមូលពន្ធគ្រប់ប្រភេទមិនមែនមានតែច្បាប់ពន្ធដារជាគោលហើយអាចប្រមូលបាននោះទេ គ្រប់សាខាពន្ធដារ ត្រូវមានផែនការ និងយុទ្ធសាស្ត្រឱ្យបានត្រឹមត្រូវ។ ពន្ធដារបានចូលរួម ចំណែកយ៉ាងសកម្ម និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការធ្វើឱ្យចំណូលពន្ធកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ នៅក្នុងឆ្នាំ ២០២១ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធតាម អនឡាញដែលប្រព័ន្ធនេះ នឹងពង្រឹងសេវាផ្នែកចាត់ចែងលិខិតប្រកាសពន្ធ ជូនអ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ធានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាសទាំងអស់ដែលនេះជាសមិទ្ធផលមួយ ក្នុងចំណោមសមិទ្ធផលធំៗជាច្រើនរបស់ អគ្គនាយកដ្ឋានពន្ធដារ លើការផ្លាស់ប្តូរឯកសារពន្ធ ទៅជាឌីជីថលដ៏ទំនើប។

សរុបជារួមមកយើងឃើញថា ទោះបីជាមានចំណុចខ្វះខាតមួយចំនួនក៏ដោយ អគ្គនាយកដ្ឋានពន្ធដារ បានខិតខំប្រឹងប្រែង និងកែលម្អរាល់ចំណុចមិនល្អទាំងនោះឱ្យកាន់តែប្រសើរឡើងថែមទៀត។ ជាក់ស្តែងលទ្ធផលដែលទទួលបាននាពេលបច្ចុប្បន្ននេះ អគ្គនាយកដ្ឋានពន្ធដារ បានប្រមូលពន្ធចូលថវិកាជាតិមាន ការកើនឡើងជារៀងរាល់ឆ្នាំ ដែលសម្រេចបានទៅតាមផែនការ ដែលរាជរដ្ឋាភិបាលបានដាក់ជូន មិនតែ ប៉ុណ្ណោះ ការប្រមូលពន្ធនៅឆ្នាំ២០២៣ នេះទទួលបានចំណូលលើសពីផែនការដែលបានគ្រោងទុកទៀតផង វាបញ្ជាក់ឱ្យឃើញថា ពន្ធដារបានអនុវត្តការងាររបស់ខ្លួនកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។ ទោះបីជាមានជោគជ័យយ៉ាងនេះក៏ដោយ អគ្គនាយកដ្ឋានពន្ធដារ នៅតែមិនបណ្តោយ ឬភ្លេចខ្លួនក្នុងការបំពេញភារកិច្ច របស់ខ្លួននោះទេ តែនឹងនៅតែខិតខំបណ្តុះបណ្តាលមន្ត្រីពន្ធដារឱ្យកាន់តែមានសមត្ថភាព បន្តការកែលម្អ ឆាប់រហ័ស។ ច្បាប់ពន្ធដារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីឱ្យដើរទាន់សេដ្ឋកិច្ចដែលកំពុងតែរីកចម្រើនយ៉ាងខ្លាំង។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **សវនកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ** រួចមក ដើម្បីឱ្យការប្រមូលពន្ធ មានប្រសិទ្ធភាពខ្ពស់ យើងអាចផ្តល់នូវអនុសាសន៍មួយចំនួន ដូចខាងក្រោមៈ

- ផ្តល់ជាចំណេះដឹងសវនកម្មពន្ធដារ បន្ថែមទៀត (ព្រោះអ្នកជាប់ពន្ធមួយចំនួនតូចនៅមិន ទាន់យល់ច្បាស់ អំពីកាតព្វកិច្ចរបស់ខ្លួន ជាហេតុធ្វើឱ្យមានការយល់ច្រឡំ ការមិនពេញចិត្ត និង ការគេចវេសមិនព្រមបង់ពន្ធ )តាមរយៈការបើកវគ្គបណ្តុះបណ្តាលឬសិក្ខាសាលាស្តីពីសវនកម្មពន្ធដារឱ្យច្បាស់លាស់បន្ថែមទៀត ដើម្បីឱ្យមន្ត្រីដកហូតពន្ធ និងប្រជាជនកាន់តែងាយ ស្រួល ក្នុងការអនុវត្តន៍ និងយល់ដឹងកាន់តែច្បាស់ ជៀសវាងពេលបង់ពន្ធធ្វើពន្ធដារឱ្យមានការខុសឆ្គង
- សំណូមពរ ដល់មន្ត្រីដែលធ្វើការដកហូតពន្ធសុំបញ្ឈប់នូវសកម្មភាព និងសម្តែងនូវឥរិយាបថ មិនសូវសមរម្យដែលជាហេតុធ្វើឱ្យប៉ះពាល់កិត្តិនាមរបស់អគ្គនាយកដ្ឋានពន្ធដារ
- សូមពង្រឹងសមត្ថភាពលើការធ្វើសវនកម្មបន្ថែមជៀសវាងការក្លែងបន្លំឯកសារផ្សេងៗរបស់ក្រុមហ៊ុនឬស្ថាប័នមួយចំនួន ដែលជាកត្តាធ្វើឲ្យមានភាពមិនស្មោះត្រង់ចំពោះការបង់ពន្ធ
- បន្តពង្រឹងការងារចុះបញ្ជីពន្ធដារ ឱ្យមានប្រសិទ្ធភាពនិងតម្លាភាព ដើម្បីជានាការផ្តល់សេវាឱ្យ បានល្អប្រសើរនិងការគ្រប់គ្រងចំណូលពន្ធមានប្រសិទ្ធភាពខ្ពស់
- បន្ថែមចំណេះដឹងទាក់ទងនឹង ការប្រកាសពន្ធតាមអនឡាញ ដល់អ្នកជាប់បន្ថែមទៀត ដើម្បីឱ្យ អ្នកជាប់ពន្ធមានភាពងាយស្រួលក្នុងការបង់ពន្ធ ចំណេញពេលវេលា ពន្ធដារប្រមូលពន្ធបានឆាប់រហ័ស និងប្រសិទ្ធិភាពខ្ពស់។

# ឯកសារយោង


- ឯកសារយោង ឯកសារផ្សេងៗក្នុងបណ្ណាល័យនៃ វិទ្យាស្ថានវ៉ាន់ដា ទាក់ទងនឹងសវនកម្មពន្ធដារ
- ឯកសារវគ្គបណ្តុះបណ្តាលស្តីពី សវនកម្មពន្ធដាររបស់សាលាជាតិពន្ធដារ
- ប្រកាសលេខ២៧០សហវ.ប្រក ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៩
- ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, មាត្រា១២៨
- សវនកម្មពន្ធដារ ( advancegroupkh.com )
- អគ្គនាយកដ្ឋានពន្ធដារ | ព្រឹត្តិបត្រពន្ធដារ (tax.gov.kh)
- និតិ - Search (bing.com)
- https://www.tax.gov.kh/en
- http://cambotax.com/taxes-law/cambodia-taxes-law/
- https://opendevelopmentcambodia.net/km/tag/phnom-penh-tax- department/
- https://en.wikipedia.org/wiki/Tax
- tax-auditing_legal-pointer_17th_kh.pdf ( gmac-production.s3-ap-southeast-1.amazonaws.com )
- 0fe50e12-23ae-457a-8894-ca205d45fdbc ( tax.gov.kh )

# ឧបសម្ព័ន្ធ
## រូបភាព ៖ ទាក់ទងនៃការសាកសួរព័ត៌មាន





# រូបភាព ៖ ប្រកាស ស្ដីពី សវនកម្មពន្ធដារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.ប្រក

**ប្រកាស**
**ស្ដីពី**
**សវនកម្មពន្ធដារ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# រូបភាព៖ មេរៀនដែលទាក់ទងនិងពន្ធដារ



**មេរៀនទី១**

## សញ្ញាណទូទៅនៃពន្ធដារ

### I. លក្ខណៈពិសេស នៃពន្ធដារ

ផ្ដើមចេញពីពេលដែលសង្គមមនុស្ស ត្រូវបានបែងចែកជាវណ្ណៈ មានការតស៊ូវណ្ណៈ និងមានការកើតឡើងនៃរដ្ឋាភិបាល ដើម្បីគ្រប់គ្រងរចនាសម្ព័ន្ធនៃប្រទេសមួយ រហូតមកដល់បច្ចុប្បន្ន ពន្ធដារ ត្រូវបានគេអនុវត្តច្រើនបែបយ៉ាង ហើយកាន់តែទូលំទូលាយ ។

**ពន្ធដារគឺជាអ្វី**? What is taxation?

១. ពន្ធ គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិ ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសសភាពសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម...និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យ តំរូវការរួមរបស់សង្គមជាតិទាំងមូល។

២. ពន្ធ គឺជារូបធាតុ នៃការប្រមូលចំណូលមួយ ដែលផ្សារភ្ជាប់ ជាមួយនិង សិទ្ធអំណាច នយោបាយរបស់រដ្ឋាភិបាល ដែលក្រិត្យច្បាប់បើជាកំណត់ ។

៣. ពន្ធ គឺជាការបង់វិភាគទាននូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងឲ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឲ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឲ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួញខុសត្រូវ ចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឲ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់ ។ និងមានសិទ្ធស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និង ត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយ ដែលមានបែងចែកក្នុងច្បាប់ ។

ពន្ធបានធ្វើឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលដែលបានប្រមូល ។បន្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងការឯកភាពគ្នា អំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយ និងផលប្រយោជន៍ របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដាត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ។

### II. លក្ខខណ្ឌ សំណុមពរនៃពន្ធដារ

#### ក. ចំពោះការគ្រប់គ្រង

ពន្ធដារ បានចូលរួមក្នុងការកែសំរួលយឿនសេដ្ឋកិច្ចជាតិទាំងមូល ដែលបានគ្រប់គ្រងដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ធ្វើការណែនាំឧបត្ថម្ភចំពោះគ្រប់សមាសភាពសេដ្ឋកិច្ចដោយសារ មូលហេតុនេះហើយរដ្ឋាភិបាល មានលទ្ធិភាពគ្រប់គ្រាន់ និងចាំបាច់បែងចែកចំណូលមួយផ្នែក របស់បណ្ដាគ្រប់សមាសភាពសេដ្ឋកិច្ច ក្នុងគោលបំណងអនុវត្តន៍នូវគោលដៅសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។

#### ខ. ទំនាក់ទំនងរបស់ពន្ធដារ

គឺជាទំនាក់ទំនងរវាងកាតព្វកិច្ច និងសិទ្ធអំណាចសង្គម ។ ប្រការនេះទៀមទារឲ្យគ្រប់សមាសភាព សេដ្ឋកិច្ច និងបុគ្គលមានកាតព្វកិច្ចចំពោះរដ្ឋាភិបាល ។ កាតព្វកិច្ចនោះនៅក្នុងទំនាក់ទំនងហិរញ្ញវត្ថុត្រូវបានអនុវត្តដោយមាត់ បង់ភាគទានមួយផ្នែកប្រាក់ចំណូលដែលរាល់សកម្មភាពរបស់វាបានបង្កើតឡើង។

**គ. លក្ខខណ្ឌចាំបាច់ នៃពន្ធដារ**

លក្ខណៈសត្យានុម័តៈ ក្រៅពីប្រមូលចំណូលថវិការដ្ឋ ពន្ធគឺជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការណែនាំ ផលិតកម្ម អាជីវកម្ម សេវាកម្ម ។ បំណែងចែកការប្រើប្រាស់ រួមចំណែកឡើងវិញនូវបញ្ហាការផលិតកម្ម បញ្ហាការសមាសមាត្រចំណូលកាន់តែសមស្រប ។

លក្ខណៈអត្តនោម័តៈ អនុវត្តការទប់ស្កាត់ សម្របសម្រួលចំណូលរវាងបណ្តាស្រទាប់ប្រជាជនចុះឈ្មោះ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ គ្រប់គ្រងបញ្ជីការហិរញ្ញវត្ថុ ថវិការដ្ឋ ធ្វើឲ្យមានស្ថេរភាពថ្លៃ និង ចរាចរណ៍ហិរញ្ញវត្ថុ ។

**ឃ.អត្ថប្រយោជន៍ នៃពន្ធដារ**

ពន្ធដារមិនត្រឹមតែជាប្រភពចំណូលដ៏សំខាន់របស់ថវិការដ្ឋតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែពន្ធដារបានផ្សាភ្ជាប់ជាមួយបញ្ហាទាំងឡាយអំពីការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ចអំពីសមាសភាពក្នុងការបែងចែកនិងស្ថេរភាពសង្គម។

ប្រសិនបើគោលនយោបាយពន្ធខុសឆ្គង អាចនាំឲ្យមានភាពអន់ថយដល់ល្បឿនសេដ្ឋកិច្ចសង្គម ផ្ទុយទៅវិញបើគោលនយោបាយពន្ធត្រឹមត្រូវ នាំឲ្យមានភាពរុងរឿងសំបូរ និងមានស្ថេរភាពយូរអង្វែងឲ្យប្រទេសជាតិយើង ។

**III. តួនាទីជាមូលដ្ឋានរបស់ពន្ធដារ**

ពន្ធដារមានតួនាទីជាមូលដ្ឋានដូចខាងក្រោម ៖

**១. បង្កើតប្រភពចំណូលថវិការដ្ឋ**

ឆ្លងតាមរយៈក្រិតច្បាប់នានា ច្បាប់សារពើពន្ធ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ស្តីអំពីកម្រិតកំណត់អត្រាពន្ធដែលក្រុមហ៊ុន សាជីវកម្ម សេវាកម្ម និង ប្រជាពលរដ្ឋ ដែលជាប់ពន្ធ ត្រូវបង់ពន្ធជូនរដ្ឋហើយប្រាក់នេះ ត្រូវបញ្ចូនចូលក្នុងថវិការដ្ឋ តាមរូបភាពជាក់ស្តែងផ្សេងៗគ្នា ។ នេះគឺជាតួនាទីសំខាន់ៗរបស់ពន្ធដារ ។ តួនាទីនេះចាប់ផ្តើមពីចំណុចពិសេសអំពីសិទ្ធអំណាចរបស់រដ្ឋាភិបាលក្នុងសង្គម ។ រដ្ឋាភិបាលបានប្រើប្រាស់ សិទ្ធអំណាចខាងរដ្ឋបាល បានដាក់ចេញនូវពន្ធដែលមានចែងបណ្តា ប្រភេទពន្ធ កម្រិតពន្ធ អត្រាពន្ធ ការណែនាំអនុវត្ត និងការកែសំរួលផ្សេងៗ។

ក្នុងគោលនយោបាយពន្ធរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសភាគច្រើន ជាទូទៅបានដាក់ចេញនូវ សំណូមពរបីដែលត្រូវឆ្លើយតប ហើយរាល់ក្រិត្យច្បាប់ ច្បាប់សារពើពន្ធ ត្រូវតែតាមដានថ្លឹងថ្លែងជាប្រចាំដើម្បីឆ្លើយតបនូវសំណូមពរទាំងឡាយ ។

**ក.** សំណូមពរបង្កើតប្រភពចំណូលឲ្យថវិការដ្ឋ ត្រូវបានស្វែងឡើងនូវបរិមាណពន្ធ ដែលប្រមូលបាន និង លទ្ធភាពឆ្លើយតបរបស់វា រាល់តម្រូវការចំណាយរបស់រដ្ឋាភិបាល។

**ខ.** ដើម្បីបង្កើនប្រភពចំណូលថវិការដ្ឋ ត្រូវតែកសាងប្រព័ន្ធពន្ធមួយឲ្យបានសមស្រប គ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពជាក់ស្តែងរបស់សេដ្ឋកិច្ចជាតិ និង ទៅតាមតំបន់សេដ្ឋកិច្ច ។

**គ.** ទន្ទឹមនោះ រដ្ឋាភិបាលត្រូវតែលើកកំពស់ប្រសិទ្ធភាពនៃប្រព័ន្ធក្បាលម៉ាស៊ីនគ្រប់គ្រង និងប្រមូលពន្ធប្រឆាំងនឹងការគេចពន្ធ លួចបន្លំពន្ធ ស៊ីសំណូកពុករលួយ និងការប្រមូលពន្ធមិនគ្រប់ជ្រុងជ្រោយ ។

**២. ជម្រុញបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ**

ត្រូវបានស្វែងឡើង នូវការសាងប្រព័ន្ធសមស្របមួយ និងស្វែងឡើងនូវបណ្តាការអនុវត្តន៍ដ៏ប្រពៃរបស់ពន្ធដារ ។ នៅបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងអន់ថយមួយចំនួន ពីមុនក្នុងរយៈពេលដែលខិតខំលើកកម្ពស់អត្រាពន្ធនៃប្រភពមួយចំនួនដូចជា ៖ **អាករលើផលរបរ ពន្ធលើចំណូលបុគ្គលិក ពន្ធលើប្រាក់ចំណេញ អាករពិសេស**

**លើទំនិញ** និងសេវាមួយចំនួន...ប៉ុន្តែមិនបានយកចិត្តទុកដាក់ដល់ ប្រភេទពន្ធមួយចំនួនទៀតដូចជា: **ពន្ធលើធនធាន ពន្ធលើដីធ្លី**... ដែលនាំឲ្យមានការប្រើប្រាស់ធនធានពាសពេញ ឥតសណ្តាប់ធ្នាប់ និងខ្ជះខ្ជាយ ។ ឧទាហរណ៍: ព្រៃឈើត្រូវបានគេកាប់បំផ្លាញ និងខ្ជះខ្ជាយ ធនធាន ហើយដែលជាហេតុបណ្តាលឲ្យវិនាសធនធានធម្មជាតិដែលជាសម្បត្តិរបស់រដ្ឋ និងអាចបណ្តាលឲ្យមានគ្រោះធម្មជាតិចំពោះប្រទេសជាតិ។

**៣. ទប់សម្រួលចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម**

-ពន្ធមានតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាសមាមាត្ររវាងអ្នកមាននិងអ្នកក្រ កុំឲ្យឃ្លាតឆ្ងាយពីគ្នាពេក ។ មានន័យថា ពន្ធដារបានកាត់បន្ថយចំណូលរបស់អ្នកដែលមានទ្រព្យធនច្រើន និងបង្កើនប្រភពចំណូលថវិកា ដើម្បីធ្វើការបែងចែកឡើងវិញឲ្យអ្នកក្រីក្រ ដោយឆ្លងកាត់តាមគោលនយោបាយចំណាយរបស់រដ្ឋាភិបាល ។

-រវាងអាជីវករដែលមានទ្រព្យសម្បត្តិ និងចំណូលខ្ពស់ ជាមួយនិងពលរដ្ឋក្រីក្រ ក៏មានទំនាក់ទំនងចំណុះ ឲ្យគ្នា ដើម្បីមានស្ថេរភាពក្នុងសង្គម ។ មានន័យថា នៅពេលដែលមានព្រំដែនមួយនៃការបែងចែកឡើងវិញហើយដែលកម្រិតយល់ដឹងយ៉ាងជាប់ហើសរបស់អាជីវករ នោះអាជីវករ ប្រជាពលរដ្ឋទាំងអស់បានត្រៀមជាស្រេច រួមវិភាគទានមួយផ្នែកចំណូលរបស់ខ្លួន ឲ្យពលសំណូមពររបស់សង្គម។ គេអាចកំណត់ក្របខណ្ឌព្រំដែននោះដោយ ឆ្លងកាត់តាមប្រតិកម្មរបស់បណ្តាអង្គភាពអាជីវកម្ម ផលិតកម្ម សិប្បកម្ម សេវាកម្មនីមួយៗ ។

ដើម្បីទប់សំរួលចំណូល និងការបែងចែកឡើងវិញនូវចំណូល រវាងបណ្តាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម ជាទូទៅ រដ្ឋាភិបាលបានបង្កើតពន្ធប្រយោល ចំពោះប្រភេទទំនិញ ឬសេវាមួយចំនួន របស់មុខសញ្ញាណាដែលមានចំណូលខ្ពស់ ជំនួសឲ្យការយកពន្ធដោយផ្ទាល់ ។ វិធីសាស្រ្តនេះល្អក្នុងវិស័យគ្រប់គ្រង និងទាំងវិស័យចិត្តសាស្រ្ត ហើយងាយស្រួលនឹងបានទទួលស្គាល់ ។

IV. **បណ្តាកត្តារួមផ្សំរបស់ពន្ធ**

គោលនយោបាយពន្ធមួយរបស់រដ្ឋាភិបាល ជាទូទៅមានកត្តារួមផ្សំដូចខាងក្រោម៖

**១.បុគ្គលជាប់ពន្ធ**( TAX PAPER )

បុគ្គលជាប់ពន្ធគឺជារូបវន្តបុគ្គល( Natural person ) ឬ នីតិបុគ្គល( legal entities )ទាំងឡាយដែលបានកត់ត្រាចូលក្នុងបញ្ជី ផលិតកម្ម អាជីវកម្ម សេវាកម្ម...របស់រដ្ឋាភិបាល ហើយរាល់សកម្មភាពផ្សេងៗ ត្រូវបានរដ្ឋទទួលស្គាល់ជាសាធារណៈ និងបានកំណត់កាតព្វកិច្ចបង់ពន្ធ ជូនរដ្ឋាភិបាលទៅតាមការកំណត់របស់អង្គការពន្ធ។

-បុគ្គលជាប់ពន្ធគឺជាបុគ្គលដែលទទួលរងពន្ធដោយផ្ទាល់ និងមានកាតព្វកិច្ចត្រូវបង់ពន្ធដោយផ្ទាល់ទៅអង្គការពន្ធទៅតាមច្បាប់ដែលបានកំណត់។

-បុគ្គលទទួលរងពន្ធគឺជាបុគ្គលដែលមានចំណូល ហើយទទួលការជះឥទ្ធិពលដោយប្រយោលពីពន្ធ។

**២.មូលដ្ឋានគិតពន្ធ**( THE BASIS OF TAXES )

មូលដ្ឋានគិតពន្ធ គឺជាខ្ទង់ចំណូលទាំងឡាយដែលចំណុះឲ្យសកម្មភាព ផលិតកម្ម អាជីវកម្ម សេវាកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងសកម្មភាពផ្សេងៗទៀត ដែលត្រូវបានចាត់ទុកជាមូលដ្ឋាន ដើម្បីគណនាពន្ធអាករ។ មូលដ្ឋានគិតពន្ធប្រែប្រួលទៅតាមប្រភេទពន្ធនីមួយៗ។

គេអាចកំណត់ប្រភេទពន្ធនីមួយៗ ផ្សេងៗគ្នា ដោយផ្អែកលើ មូលដ្ឋានគិតពន្ធខុសៗគ្នា។ ឧទាហរណ៍: ពន្ធកសិកម្ម អាករលើផលរបរ ពន្ធលើប្រាក់ចំនេញ អាករពិសេសលើទំនិញ និងសេវាមួយចំនួន ពន្ធសត្តឃាត។

**៣.អត្រាពន្ធ**( TAX RATE )

អត្រាពន្ធគឺ ជាកម្រិតដែលកំណត់ទៅលើមូលដ្ឋានគិតពន្ធ ដើម្បីធ្វើជា បង្អែកក្នុងការគណនាប្រាក់ពន្ធអាករ។ អត្រាពន្ធ គឺជាកម្រិតដែលបានកំណត់ ត្រូវតែបង់ពន្ធជូនរដ្ឋាភិបាល នៅលើមួយឯកតាមូលដ្ឋានគិតពន្ធ។

អត្រាពន្ធចែកចេញជាច្រើនប្រភេទដូចជា:

ក. អត្រាពន្ធគិតតាមសមាមាត្រជាភាគរយ គឺជាអត្រាពន្ធ ប្រមូលតាមសមាមាត្រជាភាគរយ ទៅលើមូលដ្ឋានគិតពន្ធ នៃប្រភេទ ពន្ធនីមួយៗ ។

ខ. អត្រាពន្ធកំណើនតាមថ្នាក់ គឺជាអត្រាពន្ធដែលគណនាទៅតាមសមាមាត្រជាភាគរយ ហើយដែលកើនឡើងជាបន្តបន្ទាប់ ព្រមជាមួយនឹងការកើនឡើងនៃចំណូលជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

គ. កម្រិតប្រមូលថេរ គឺជាកម្រិតប្រមូលថេរ ទៅលើឯកតាផលិតផលទំនិញ អចលនទ្រព្យផ្សេងៗ ដែលត្រូវជាប់ពន្ធ។

**៤.ឯកតាគិតពន្ធ**( THE UNIT OF TAX)

ឯកតាគិតពន្ធ គឺជាឯកតាដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមធ្យោបាយទូទាត់ពន្ធ។ យោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រិតច្បាប់ និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ឯកតាគិត ពន្ធត្រូវបានគិតជាប្រាក់រៀល និងប្រាក់ដុល្លារ ប៉ុន្តែមានប្រទេសមួយចំនួនអាចគិតជា វត្ថុ ឧទាហរណ៍ គិតជាគីឡូក្រាម។

**៥.តម្លៃគិតពន្ធ**

តម្លៃគិតពន្ធគឺជាថ្លៃទីផ្សារ ឬថ្លៃ CIF(Cost Insurance and Freight) FOB(Free On Board) ដែលមានកត់ត្រានៅក្នុងវិក័យប័ត្រ ដោយឆ្លងកាត់តាម SGS(Societe Generale de Surveillance) ឬជាតម្លៃដែល ត្រូវបានកំណត់ឡើងដោយ អង្គការគយ ចំពោះប្រភេទទំនិញ ដែលត្រូវបានអនុញ្ញាតិ ឲ្យ ធ្វើការនាំចេញ នាំចូលដោយឆ្លងកាត់តាមច្រកព្រំដែន។

តម្លៃគិតពន្ធ គឺជាថ្លៃទីផ្សារ ឬជាតម្លៃដែលកំណត់ដោយក្រសួងហិរញ្ញវត្ថុ ទៅលើទ្រព្យសម្បត្តិ ផលិតផលទំនិញ ឬសេវា និងមធ្យោបាយដឹកជញ្ជូន ដែលត្រូវជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

**៦.ការលើកពន្ធ**( TAX EXEMPTION)

ការលើកលែងពន្ធ គឺជាការកំណត់ទាំងឡាយរបស់រដ្ឋាភិបាលដែលមានចែងក្នុងច្បាប់ អំពីករណីបង់ពន្ធដែលជាផលប្រយោជន៍ដល់បុគ្គលជាប់ពន្ធ។

-រាល់ករណីដែលត្រូវបានលើកលែងពន្ធទាំងស្រុង ឬក៏ត្រូវបានលើកលែងពន្ធមួយផ្នែក អាស្រ័យទៅតាមលក្ខណ:សម្បត្តិរបស់អាជីវកម្ម។

-ការលើកលែងពន្ធបានស្តែងតាមរយ:គោលនយោបាយរបស់រដ្ឋាភិបាល ចំពោះបុគ្គលជាប់ពន្ធ ដើម្បីលើកទឹកចិត្តដល់អ្នកវិនិយោគ ក្នុងស្រុក និងបរទេស ផលិតកម្ម អាជីវកម្ម សេវាកម្ម និង អនុវត្តនូវ សមភាពសង្គម។

**៧.បែបបទបង់ពន្ធ**

បែបបទបង់ពន្ធ គឺជាការកំណត់ទទួលខុសត្រូវជាធរមាន និងបែបផែននៃការបង់ពន្ធចូលថវិការដ្ឋ របស់បុគ្គលជាប់ពន្ធ។ គឺជាបែបបទ ធ្វើលិខិតប្រកាស ជូនទៅអង្គការពន្ធ តាមកាលកំណត់ នៃប្រភេទពន្ធនីមួយៗ និងជាវិធីសាស្រ្តប្រមូលប្រាក់ពន្ធ ដែលផ្សាភ្ជាប់ជាមួយក្របខណ្ឌនៃសិទ្ធអំណាច ការទទួលខុសត្រូវនៃស្ថាប័នទាំងឡាយ ដែលមានការពាក់ព័ន្ធ ។